# សម្ភាសន៍ជាមួយឈ្មោះ មាស គុណ ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ «ពេទ្យ»

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិវត្តថ្មី ឃុំតាបេះ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

សព្វថ្ងៃរស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០១:៥៣:៥៤

៤៣ទំព័រ

ធានី ៖ ថ្ងៃនឹងទី២០ ខែ១០ ២០១០ ។ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ពួកខ្ញុំមកនេះគ្រាន់តែចង់សាកសួរពូពីប្រវត្តិរបស់ពូដែលពូបានឆ្លងកាត់រហូតមកដល់ឆ្នាំ៧៩ ហើយបានជួបរឿងប្រទះរឿងអីខ្លះ ។ ហើយរឿងរ៉ាវដែលពូបានប្រាប់ខ្ញុំទាំងប៉ុន្មាន ពួកខ្ញុំសុំអនុញ្ញាតិយកទៅធ្វើជាសៀវភៅ ក៏ដូចជាប្រាប់ក្មេងៗនិងអ្នកសិក្សាស្រាវជ្រាវផ្សេងៗយកទៅប្រើប្រាស់បានទេ?

គុណ ៖ អឺ! អត់អីទេធ្វើម៉េចជាក់ស្តែង យើងនិយាយតាមជាក់ស្តែងអ្វីដែលយើងធ្វើកន្លងទៅ ហើយយើងបានអនុវត្ត ។

ធានី ៖ ខ្ញុំសុំថតជាសំលេង ក៏ដូចជារូបថតបានទេ?

គុណ ៖ ថតវាខ្លាចខ្ញុំនិយាយទៅវាជ្រុលខ្លះខុះខាតខ្លះ ប៉ះពាល់ដល់រាជរដ្ឋាភិបាលយ៉ាងម៉េច ។

ធានី ៖ ចង់សួរពូអនុញ្ញាតិឲ្យខ្ញុំថតជាសម្លេងក៏ដូចជារូប?

គុណ ៖ តែបើបេះថតគិតជាតម្លៃខ្ញុំអត់ឲ្យថតទេ ។

ធានី ៖ គិតតម្លៃម៉េច?

គុណ ៖ ព្រោះកន្លងទៅអង្គការផ្សេងៗសុំមកថត សុំគិតតម្លៃថតអត់មានលុយជូនទេ តែបើខ្ញុំនិយាយតាមជាក់ស្តែង ថាអ្វីដែលខ្ញុំឆ្លងកាត់ គឺខ្ញុំនិយាយជូនបាន ។ ក្មួយឯងសុំថតជាសំលេងអ៊ំហើយអ្វីៗដែលអ៊ំឆ្លងកាត់មក អ៊ំជម្រាបជូនតាមការជាក់ស្តែង ទារលុយពីអ៊ំក៏អ៊ំគ្មានលុយឲ្យដែរ ។

ធានី ៖ មិញអីចឹងការដែលលុយកាក់អីចឹង ពួកខ្ញុំអត់មានទេ ខាងពូក៏អត់មានដែរ ។

គុណ ៖ បាទ!

ធានី ៖ យើងទាំងពីរនាក់អត់មានទាក់ទងនឹងរឿងលុយកាក់អីទេ យើងជជែកគ្នាដើម្បីធ្វើជាសៀវភៅពីរឿងរ៉ាវពីពូ?

គុណ ៖ បាទ!

ធានី ៖ អនុញ្ញាតិថតជារូប ក៏ដូចជាថតជាសម្លេងរបស់ពូបានអត់?

គុណ ៖ អត់អីទេ បើអត់គិតលុយ គិតកាក់ខ្ញុំបាន ។

ធានី ៖ ពូឈ្មោះអី?

គុណ ៖ ខ្ញុំឈ្មោះ មាស គុណ ។

ធានី ៖ ឆ្នាំនឹងអាយុប៉ុន្មាន?

គុណ ៖ គិតទៅ៥៣ ។

ធានី ៖ ពូមានស្រុកកំណើតនៅណា?

គុណ ៖ ខ្ញុំនៅ បើមែនទែនខ្ញុំនៅខេត្តកំពង់ឆ្នាំង ។

ធានី ៖ នៅភូមិឃុំអីដែរ?

គុណ ៖ កំពង់ឆ្នាំង ជិតកំពង់ស្ពឺ ។

ធានី ៖ នៅភូមិឃុំអីដែរ?

គុណ ៖ ភូមិវត្តថ្មី ឃុំតាចេះ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ធានី ៖ សព្វថ្ងៃពូរស់នៅណាវិញ?

គុណ ៖ ខ្ញុំរស់នៅបច្ចុប្បន្ន គឺស្រុកម៉ាឡៃ ភូមិសង្កែ និយាយរួមភូមិសង្កែ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឃុំអីដែរ?

គុណ ៖ ឃុំបឹងបេង ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

គុណ ៖ ឪពុកខ្ញុំឈ្មោះ ជ្រែង ប៉ុនគាត់ស្លាប់អស់ហើយ ។

ធានី ៖ អីគេជ្រែង?

គុណ ៖ មិន ជ្រែង ។

ធានី ៖ គាត់ស្លាប់ដោយសារអី?

គុណ ៖ មែនទែននិយាយវាធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក ព្រោះគាត់ស្លាប់ទៅអត់អាហារសម័យការគ្រប់គ្រងប៉ុលពត...។ ម្តាយស្លាប់ក្នុងសង្គមសម្តេចឪ អត់ទេ ប៉ុន្តែឪពុកខ្ញុំស្លាប់វេទនាបំផុត ។

ធានី : ឆ្នាំប៉ុន្មាន?

គុណ : ៨៣ ឪពុកខ្ញុំ ។

ធានី : ៨៣ ឬ៧៣?

គុណ : ៧៣ ។

ធានី : ៧៣ ខ្មែរក្រហមកាន់កាប់ហើយ?

គុណ : កាន់កាប់ហើយ គេធ្វើបដិវត្តសង្គមនិយម ។

ធានី : បដិវត្តសង្គមនិយមម៉េច?

គុណ : បដិវត្តសង្គមនិយម ខ្ញុំចង់និយាយថា ប៉ុលពត គ្រប់គ្រងអំណាចទាំងអស់ ប្រើកម្លាំងមនុស្ស ជាគ្រឿងចក្រទាំងអស់ ។ ដូច្នេះ ងាប់នៅកន្លែងការដ្ឋានទាំងអស់ គ្មានបាយ គ្មានអីហូបទេ ហូបតែបបរទេ ។ ហើយបបរនឹងមានព្រលិត ត្រកួន ហើយនឹងអង្ករ២-៣កំប៉ុងក្នុងមួយខ្ទះ ។ ដូច្នេះដល់ហូបទៅគ្នាភាគច្រើនស្លាប់អស់ នេះជាទុក្ខវេទនានៅក្នុងសង្គមនោះណា ។ បាននេះជាបញ្ហាជាក់ស្តែង អ៊ំសុំនិយាយពីបញ្ហានេះ ការដឹកនាំក្នុងសង្គមនេះវាអីចឹង បើយើងមិនរណប តាមសង្គម គឺស្លាប់ទាំងអស់ ។ រណបហើយ ក្នុងមួយថ្ងៃធ្វើម៉ោង១២ កុមារកុមារីប៉ុននេះ អត់មានជួបឪពុកម្តាយទេ នៅក្នុងកន្លែងមណ្ឌលកុមារគេផ្សេងទៀត ដែលគ្មានឪពុកម្តាយ តែម៉ោង៤-៥ត្រូវតែទៅ ដល់មកវិញហូបបបរគ្មានបាយហូបទេ ។

ធានី : ប្រជាជនថ្មីមកដល់ឥឡូវ ពេលឪពុកពូស្លាប់?

គុណ : ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំចេញផុតទៅ កាលនឹង៧៩វៀតណាមចូលមក ដល់ខ្ញុំរស់នៅក្រោមការគ្រប់គ្រងរបស់ប៉ុលពត ។ យើងត្រូវចេញ បើមិនចេញគេអារក ចេះខ្លាចចេះតែរត់ៗមកដល់ព្រំដែន ។ ដល់ព្រំដែននេះ គឺគ្មានពន្លឺថ្ងៃទេ សុទ្ធតែព្រៃ ៧៩នឹង ។ នាំគ្នាតាំងទីកលំនៅ គ្រួនក្បាលត្រមែងៗ បាយមានតែគ្រាន់តែវាឈឺ ។ បាយមានអង្គការកាកបាទក្រហមអន្តរជាតិមកចែកអំណោយ ទទួលយកមក ។ ដល់ការឈឺគ្រុន ម្នាក់ៗសង់ខ្ទមកាត់... គ្មានមនុស្សរស់នៅទេ ។ ដល់មកទល់បច្ចុប្បន្ននេះ ប្រែក្លាយពីព្រៃភ្នំក្រោមថ្ម មកប្រែក្លាយជាដំណាំស្រុក ។ កាល៧៩ កងទ័ពវៀតណាមវ៉ៃបុកមកខ្លាំងមក អ៊ំមានតួនាទីជាអ្នកដឹកជញ្ជូនឲ្យកងទ័ព ទាំងអស់គ្នា ឲ្យតែអ្នកណាមកនៅព្រំដែន គឺខ្មែរក្រហមឲ្យដឹកជញ្ជូនទាំងអស់ ដឹកជញ្ជូនស្បៀងអាហារទាំងអស់ ។ ដល់វៀតណាមវ៉ៃមក កងទ័ពខ្មែរក្រហមមិនអាចទទួលបាន ក៏ធ្លាក់ទៅដល់ដីថៃ ។ ថៃគេឲ្យប្រកកោន ជាមូលដ្ឋានរបស់យោធា មួងម្កាលនាំគ្នាមក ដល់ពេលវៀតណាមចេញផុតពីនេះទៅ បាននាំគ្នាឡើងមកកាន់កាប់នៅភូមិនេះវិញ ។ ដល់មកនៅកាន់ក្តាប់ភូមិនេះវិញ មនុស្សគ្រោះថ្នាក់ច្រើនណាស់ ព្រោះវៀតណាមដាក់មីងច្រើន ។ ខ្លះក៏ស្លាប់, ខ្លះក៏កាត់

ដៃកាត់កាត់ជើង, ពិការភ្នែកខ្វាក់ខ្វិនទាំងអស់...។ ហើយអ៊ំក៏មានគ្រោះថ្នាក់... រាវមីនរាវអី មកនៅកន្លែងភូមិយើងវិញ។ មកដល់ទល់ថ្ងៃនេះ យើងធ្វើសមាហរណកម្ម ដែលសម្ដេចនាយកហ៊ុន សែន គាត់បានផ្សះផ្សាជាតិ មករស់នៅវិញទៅ ក៏នាំគ្នាមករស់នៅនេះ។ ដូចថាបញ្ហាសន្តិសុខក្នុងសង្គមក៏ល្អដែរ។ ឲ្យប្រជាជនបង្កបង្កើនផល ធ្វើម៉េចធម្មជាតិគៀបសង្កត់ដែរ បើថាធម្មជាតិមិនគៀបសង្កត់ ប្រជាជនរស់នៅកន្លែងនេះក៏រាំរីកចំរើនដែរ ក្នុងការដឹកនាំរបស់សម្ដេច។ ជាក់ស្ដែងនៅកន្លែងនេះ អ៊ំនិយាយឲ្យត្រង់តែម្ដង អ៊ំអត់មានខ្លាចអីទេ គឺអ៊ំគាំទ្រសម្ដេចនាយកពេញទី គឺឲ្យប្រជាជន ដែលផ្ដាច់ខ្លួនមករួបរួមនេះ មានសេរីភាព មានសិទ្ធិរកស៊ី ហើយមិនគៀបសង្កត់ដល់សិទ្ធិប្រជាជនទេ ធ្វើម៉េចឲ្យប្រជាជនរកស៊ីឲ្យបាន។ គណបក្សនេះ ដឹកនាំ និងផ្សះផ្សាជាតិ អនុគ្រោះគ្នា មិនប្រកាន់ចាប់ទោសកំហុសគ្នា។ កាលនោះក្រោមការដឹកនាំ និងផ្សះផ្សាជាតិរបស់សម្ដេចនាយកកន្លងមកនេះ សុំជូនពត៌មានឲ្យបានដឹងតិច ព្រោះកន្លងទៅមានតែផ្ទះស្បូវទេ ហើយឥឡូវនឹងម្នាក់ៗបានប៉ុននឹងឯង ដោយសារអីសម្ដេច គាត់ថាធ្វើម៉េចបងប្អូននៅកន្លែងណា នៅកន្លែងនឹង ហើយធ្វើព្រៃតិចតួច ដែលបងប្អូនត្រូវតែរុករាន ខុសពីកន្លែងបរិស្ថានដែរ។ កន្លែងណាបរិស្ថាន ជាមូលដាន តែកន្លែងណាក្រៅបរិស្ថានធ្វើម៉េចបងប្អូនកាប់ទៅ។ ចំនុចល្អសម្រាប់យើងនឹងថៃនេះដែរ បើយើងកន្លងមកកាលសម័យសង្គមនិយម ថៃវាលួចចូលដីយើងមិនចេះតិចគឺឡូ។ សម័យយើងមកនៅតាមព្រំដែន ថៃអត់ហ៊ានមកទេ។ ទឹកដីយើងគង់វង្សដោយសារអី កាលពីដើមភូមិថៃ នៅនេះដើមឫស្សីនេះ គគ្រឹកគគ្រេងនៅកន្លែងនឹង។ ដល់យើងមកនៅថៃអត់ហ៊ានមកនៅ ដល់នេះជាមោទនភាពមួយរបស់សម្ដេចដែរ បានបញ្ជូនប្រជាជនមកនៅតាមព្រំដែនការពារទឹកដីរបស់ខ្លួន...។ បញ្ហាសំខាន់កូនទៅលក់ពលកម្ម ទល់ល្ងាច។

ធានី : ម្ដាយពូឈ្មោះអី?

គុណ : អៀម ដើ។

ធានី : គាត់នៅរស់ទេ?

គុណ : ស្លាប់អស់ហើយ។

ធានី : ស្លាប់ពេលណា?

គុណ : ស្លាប់កាលសម័យសង្គមរាស្ត្រនិយម តែបើឪពុកខ្ញុំស្លាប់ក្នុងសម័យប៉ុលពត។

ធានី : ម្ដាយពូស្លាប់ឆ្នាំប៉ុន្មាន ចាំទេ?

គុណ : ខ្ញុំមិនអាចចាំបានដែរ ព្រោះខ្ញុំនៅតូចដែរ ព្រោះខ្ញុំអត់ដឹងម្ដាយស្លាប់មិនដឹងប៉ុន្មានឆ្នាំ តែបើឪពុកខ្ញុំដឹង។

ធានី ៖ គាត់ស្លាប់ឆ្នាំ៧៣?

គុណ ៖ បាទ!

ធានី ៖ គាត់ស្លាប់នៅណា?

គុណ ៖ ស្លាប់នៅភូមិតាចេស ឃុំវត្តថ្មី ។

ធានី ៖ ស្លាប់នៅស្រុកកំណើត?

គុណ ៖ បាទ! ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ធានី ៖ កាលនឹងពូនៅក្បែរគាត់ដែរ?

គុណ ៖ ខ្ញុំអត់ទេ គេរុញ ។

ធានី ៖ រុញទៅណា?

គុណ ៖ រុញមកព្រំដែន បែកបាក់គ្រួសារ ។

ធានី ៖ ម៉េចបានពូដឹងថា ឪពុកពូស្លាប់ឆ្នាំ៧៣ ។

គុណ ៖ ព្រោះមានបងមួយនៅនឹង ឈ្មោះបង មិន ផន បងបង្កើត គាត់ទៅតាមរកប្អូនដល់ណា ។ ដល់ជួបខ្ញុំ២០០០នេះកាលអ៊ុនតាក់ចូលមក អញខំដើររកឯង ឪពុកស្លាប់ស្រែករកតែឯង ។

ធានី ៖ ឆ្នាំប៉ុន្មាន២០០០ អ៊ុនតាក់ចូលមក?

គុណ ៖ បាទ! អត់ទេ អ៊ុនតាក់ចូលមុន២០០០ ។ តែឆ្នាំ២០០០ គាត់ដើររកខ្ញុំ ។ ដល់២០០២ ខ្ញុំទៅជួបគាត់ គាត់រាយរាប់ប្រាប់ទាំងអស់បានស្រណោះឪពុក មិនគួរណាបែកពីគាត់ដែរ កាលនឹងវាខ្ញុំមិនមែននាទីជាកងទ័ព ជាអីទេ មែនទែនទៅគឺជាកងចល័តធ្វើពលកម្មតាមប្រព័ន្ធភ្លឺស្រែ ដល់ពេលមានសភាពការណ៍កើតមក៧៩ ក៏គេរុញមកៗក៏ព្រាត់ប្រាសឪពុកម្តាយបងប្អូនបានរសាត់អណ្តែតមកដល់កន្លែងនេះ ។

ធានី ៖ ពូចូលធ្វើទ័ពពេលណា?

គុណ ៖ ខ្ញុំអត់មានធ្វើទេ ធ្វើកងចល័ត ។

ធានី ៖ កងចល័តនៅឆ្នាំណា?

គុណ ៖ កងចល័តមែនទែនទៅ៧៦ ។

ធានី ៖ នៅណា?

គុណ ៖ ខត្តុង្គ ពញាពុចុងវាប់ហើយ ផ្សារត្រាចអីនឹង៧៦ ។ ដូច្នេះ គេកែណ្ឌកន្លែងណាទៅធ្វើកន្លែងនឹង លើកប្រព័ន្ធភ្លឺស្រែ ។

ធានី ៖ មុនពេលធ្វើកងចល័ត ពូធ្វើអី?

គុណ ៖ ប្រជាពលរដ្ឋធម្មតា ។

ធានី ៖ នៅណា?

គុណ ៖ នៅភូមិតាចេស ឃុំវត្តថ្មី ធម្មតាខ្ញុំទើបនឹងសឹកពីបួស ។

ធានី ៖ ពូបួស?

គុណ ៖ បាទ!

ធានី ៖ បួសនៅណា?

គុណ ៖ បួសវត្តថ្មី ។

ធានី ៖ ពេលណា?

គុណ ៖ បួសនឹងប៉ុន្មានទេ ដូចមិនចាំដែរ កាលនឹងប្រហែលជា៦៧-៦៨ ។ ហ្នឹងហើយចាត់ទុក៦៨ចុះ

ធានី ៖ ហើយបួសដល់ពេលណា បានពូសឹក?

គុណ ៖ ឆ្នាំ៧០សឹកបណ្តោយ ។ ដល់សឹកទៅ អន្តការពីលើយកមកឲ្យសឹកចូលកងចល័ត ។ កងបង្កើនផល យើងក្លាយភេទពីបុព្វជិតទៅជាគ្រហស្ថ យើងត្រូវខំកសាងប្រទេសនយោបាយ ។ ហើយខំធ្វើកងចល័តនឹង មែនទែនទៅ២០០-៣០០នាក់ គេចាត់ទុកកងតូចលងធំគគោក ។

ធានី ៖ ពូប្រាប់ថាឈប់បួសនៅឆ្នាំ៧០?

គុណ ៖ ហ្នឹង ខ្ញុំបួសនៅឆ្នាំប៉ុន្មានទេ តែឥឡូវវាភ្លេចដែរ វាមិនសូវគិតគូរអី ។

ធានី ៖ បន្ទាប់មកទៀតពូបួសហើយចូលកងចល័ត?

គុណ ៖ បាទ!

ធានី ៖ ពូប្រាប់ខ្ញុំមិញថា កងចល័តនៅឆ្នាំ៧៦?

គុណ ៖ ហ្នឹងហើយ៧៦ ។

ធានី ៖ ចុះមុននឹង ធ្វើអីគេ?

គុណ ៖ មុននឹង ខ្ញុំបួសហើយធ្វើប្រជាពលរដ្ឋធម្មតា ធ្វើស្រែចំការធម្មតា ។

ធានី ៖ បួសឆ្នាំ៦៨ សឹកឆ្នាំ៧០ ហើយ?

គុណ ៖ ហើយមកធ្វើកងចល័ត ។

ធានី ៖ កងចល័តអីគេ?

គុណ ៖ កងចល័តចង់និយាយថា កាលនឹងគេកែណ្ឌកម្លាំងលើកប្រព័ន្ធភ្លឺ ធ្វើស្រែចំការវិញ ។

ធានី ៖ នៅណាវិញ?

គុណ ៖ កងចល័តនៅដដែល ភូមិស្រុកដដែល ។

ធានី ៖ ពូស្គាល់ប្រធានរបស់ពូ កងចល័ត?

គុណ ៖ ប្រធានខ្ញុំៗស្គាល់ ប្រធានខ្ញុំកាលនឹង គាត់ឈ្មោះ តាអួង តែគាត់ស្លាប់ហើយ ។

ធានី ៖ កងចល័តប្រចាំអីគេ?

គុណ ៖ ប្រចាំស្រុក ។

ធានី ៖ ស្រុកអីគេ?

គុណ ៖ ស្រុកកំពង់ត្រឡាច ។

ធានី ៖ គេហៅស្រុកលេខប៉ុន្មានដែរ?

គុណ ៖ ស្រុក១៨ ។

ធានី ៖ ហើយពូទៅធ្វើការដល់ណា?

គុណ ៖ មែនទែនទៅ កំពុងទំលើកប្រព័ន្ធភ្លឺស្រែសម័យនៅខត្តុង្គកំពង់លួងនឹងទៅ ។ ដល់៧៩យួនវៃចូលមក គេរុញមកខាងលិចរហូតមកទល់សព្វថ្ងៃនឹង ។

ធានី ៖ ពូរត់មកតាមអ្នកណាគេ?

គុណ ៖ ខ្ញុំរត់មែនទែនទៅ៣ខែ រត់មកវេទនា បើនិយាយមែនទែនទៅ រត់មកខេត្តកំពង់ឆ្នាំ ធ្លាក់មកខេត្តពោធិ៍សាត់ៗឡើងភ្នំចុះភ្នំ គ្មានពេលឃើញពន្លឺខែទេ ។ ដល់ធ្លាប់ពីពោធិ៍សាត់នឹងមក ធ្លាក់មកនៅកោះកុង ។ ដល់វាអស់អាហារហូបទេ ដល់អីចឹងអត់មានអាហារហូបទេ ចូលទៅដីថៃៗគេយកទៅដាក់ជំរុំមួយ គេហៅជំរុំខាវឡាង ជំរុំស្ដេច ។

ធានី ៖ ខាវឡាង?

គុណ ៖ ហ្នឹងហើយជំរុំខាវឡាង ជំរុំនឹងនៅខេត្តត្រាង ស្រុកក្ងយៃ៉ តែឃុំអត់ដឹង នៅស្រុកថៃ ។ ថៃគេឲ្យយើងរស់នៅសុខដុមរមនាមានជំរុំ២០០១ ជំរុ២០០២ គេឧបត្ថម្ភប្រជាពលរដ្ឋទាំងអស់នឹង ។ ដល់ក្នុងអង្គការមួយគណបក្សរបស់ថៃនឹង កាលនឹងនៅថៃមានក្រហម មានខៀវមានស គេត្រូវជាមួយខាងអង្គការខ្មែរក្រហម គេអំពាវនាវឡើងភ្នំវិញ ។ គេបែកអង្គរ បែកទៃ ឲ្យយើងចេញទៅធ្វើការតស៊ូ កាលនឹងស្រុកថៃមានលោកសក្តិ៦ ។ គេអប់រំយើង យើងគ្មាននៅប្រទេសទី៣ទេ ដូច្នេះយើងនាំគ្នាវិលមកវិញតស៊ូ ។ ដល់អីចឹងខ្ញុំវិលត្រឡប់មកវិញ ខ្ញុំអត់ទៅណាទេ ប្រទេសទី៣ក៏ខ្ញុំមិនទៅដែរ ។ ខ្ញុំវិលមកវិញនៅស្រុកកំរៀង គេប្រើដឹកជញ្ជូនដល់អីចឹងសភាពការណ៍ ខ្មែរក្រហមក៏គ្មានមូលដ្ឋានរឹងពឹង សេដ្ឋកិច្ចគ្មានរឹងពឹង ក៏នាំគ្នាមករស់នៅ អង្គការសហប្រជាជាតិក៏ដឹកយើងមកចូលជំរុំ២០០១វិញ នៅម៉ៃរូត២០០១ ។ ដល់អីចឹង ខាងអាមេរិច បារាំង អ៊ីតាលី គេមកសម្ភាសន៍ ដល់យើងសម្ភាសន៍អត់ជាប់ គេរុញយើងមកនៅខាវអ៊ីដាងវិញ ។ ខ្ញុំថាឥឡូវខ្ញុំធ្វើមាតុភូមិនិវត្តដោយស្ម័គ្រចិត្តហើយ ព្រោះខ្ញុំអត់មានលទ្ធភាពទៅប្រទេសទី៣ទេ ។ ខ្ញុំមកគេរុញមកនៅភូមិដូងនេះ នៅឆ្នាំ៨៣ ។ ខាងច្រកនេះគេហៅច្រក១០២ ស្រុកម៉ាឡៃ ហើយក្រោមការដឹកនាំរបស់លោក យ៉ែម អភិបាលច្រក

នឹង ។ ហើយមេកងទ័ពដែលគ្រប់គ្រងទ័ពនៅកន្លែងនេះ គឺមានលោក សុខ ភាព ។ គាត់ចាត់ចែងនាំប្រជាជននៅតាមព្រំដែន នាំគ្នាចាប់ដីចាប់ធ្វីធ្វើភូមិករ ទៅ ។ ដល់រហូតមកដល់៧៩ យួនវ៉ៃបុកមកធ្លាក់នៅដីថៃម្ដងទៀត ។

ធានី : ៧៩ ទៀត?

គុណា : ៧៩នឹងយួនបុកមកខ្លាំង ។ ចុះ៧៩កាលយើង ៨១ ៨២ ៨៣ យើងមិនរស់នៅនេះ រស់នៅជំរុំ ដល់ធ្វើមាតុភូមិនិវត្តន៍មកដល់៧៩ យួនវ៉ៃបុកខ្លាំង?

ធានី : ៧៩ ឬ៨៩?

គុណា : ៨៩ ខ្ញុំច្រឡំ ។ មានអឹកសាងភូមិដ្ឋាន ហើយផ្ទះខ្ញុំឈើព្រៃ ដូចខ្ញុំនិយាយអីចឹង ដើមឈើធំៗអស់ៗ កន្លែងនេះ ទាំងផ្លូវដីរ ត្រឹមចង្កេះដីរផាប់ ដល់កសាងភូមិករ ។ ៧៩យួនវ៉ៃបុកម្ដងទៀត ចូលដីថៃ ។ ដល់៨៦បានវិលមកវិញ ព្រោះយើងទៅនៅជំរុំថៃ គេឲ្យឈ្មោះថាជំរុំ៨៥ ។

ធានី : អីចឹងនៅ៨៣ ពូនៅភូមិដូង?

គុណា : បាទ!

ធានី : នៅធ្វើអីគេ?

គុណា : នៅកងដីរបណ្ដោយ កងដឹកជញ្ជូន ។

ធានី : ពូមានដឹកដីរ?

គុណា : អត់មានដីរ ប៉ុន្តែយើងដឹកដូចដីរ គេប្រៀបធៀបទៅអីចឹង ។

ធានី : ពូនៅ៨៣នៅភូមិដូង ដល់ត្រឡប់ពី៨៣ពូទៅណាវិញ ទៅ៨៥ ទៅជំរុំ?

គុណា : ជំរុំ ។

ធានី : ទៅជំរុំ៨៥?

គុណា : បាទ!

ធានី : ហើយនៅចន្លោះពី៨៣-៨៥ ពូធ្វើអីគេ?

គុណា : ធ្វើតែប្រជាជនដឹកជញ្ជូនរហូតនឹង គេហៅកងដីរ ។

ធានី : អត់មានដីរ?

គុណា : មានដីរមកពីណា ។

ធានី : ដឹកជញ្ជូនទៅណាខ្លះ?

គុណា : ដឹកជញ្ជូនគេឲ្យទៅខាងទ័ពខ្មែរក្រហមនឹង ។

ធានី : នៅខាងណាខ្លះពេលពូដឹក?

គុណ : ទៅតាគង់ ។ យើងរើគេនឹងកងទ័ពរាជរដ្ឋាភិបាល ។

ធានី : ហើយពេលនឹងពូមានគ្រួសារឬនៅ?

គុណ : ខ្ញុំមានតាំងពី៧៨ ។

ធានី : ឆ្នាំ៧៨នៅពេលណា?

គុណ : ខ្ញុំនៅកោះកុង ។

ធានី : នៅធ្វើអីគេ?

គុណ : ខ្ញុំមានធ្វើអី មែនទែនទៅខ្ញុំធ្វើកខាងបុគ្គលិកពេទ្យ ។

ធានី : ៧៨ បុគ្គលិកពេទ្យនៅកោះកុង?

គុណ : បាទ!

ធានី : ពេទ្យអីគេ?

គុណ : ពេទ្យខ្ញុំគ្មានអី បើរៀនសូត្ររៀនមែនទែន ខ្ញុំរៀនវះកាត់សព្វបែបយ៉ាងទាំងមុខជំនាញ ។ ដល់៧៩ វៀតណាមរត់ចូលមករប៉ាត់រប៉ាយមកទល់ឥឡូវ ។ ហើយនាងឯងឃើញកោះកុង នៅមន្ទីរពេទ្យកោះកុង ទៅមើលដើមកញ្ចាណាៗ ដើមគីនីន គឺអុំអ្នកដាំ ដើមដូងដាំ ដែលបដិវត្តសង្គមនិយម ធ្វើការពេលវេលាអត់មានទំនេរបានទេ គឺដាំរហូត ដាំមិនឲ្យសល់មួយចំអាម ទៅមើលកោះកុងឃើញនៅជុំវិញមន្ទីរពេទ្យ ។

ធានី : ពូធ្លាប់អញ្ជើញទៅម្ដងទៀតដែរ?

គុណ : ខ្ញុំមិនដែលទៅទេ ព្រោះវាឆ្ងាយពេក ។ សង្គមនឹង បើយើងមិនធ្វើអត់បានទេ ។

ធានី : ពូធ្វើពេទ្យនៅឆ្នាំ៨៨(៧៨) ឬក៏មុន?

គុណ : ខ្ញុំបើមែនទែនទៅ តាំងពីឆ្នាំ៧០នោះ ។

ធានី : ៧០ធ្វើពេទ្យ?

គុណ : ខ្ញុំធ្វើពេទ្យ ខ្ញុំរៀនសហការជាមួយកងទ័ពវៀតណាមមកបង្រៀន ។

ធានី : ពូថានៅពេទ្យនៅឆ្នាំ៧៨ បានរៀបគ្រួសារ?

គុណ : បាទ! ខ្ញុំរៀបចំគ្រួសារនឹងក្នុងសង្គមប៉ុលពតទេ នៅឆ្នាំ៨៨(៧៨) ។ ដល់៧០នេះវៀតណាមចូលមកក៏រសាត់អណ្ដែតមករហូត ហើយនាទីខ្ញុំជាប្រជាពលរដ្ឋសុទ្ធ ដឹកជញ្ជូនក្រោមការដឹកនាំរបស់របនឹង គេប្រើទៅណាក៏ទៅៗ ។ ហើយនយោបាយអី បើយើងមិនរត់ទេ គេមកកាប់សម្លាប់ មនុស្សចេះរត់មក វេទនារបស់យើង តាមព្រៃក្រោមដើមឈើក្រោមថ្ម បើនិយាយមែនទែនតាមមើលមួយស្លាប់អស់បាយ ។ ហើយអុំហូបតែកូមស្លាទេ ក្អួត ហើយផ្ទៃសំរោងដល់ឃ្លានពេកគ្មានបាយហូបទេ មកដល់លើភ្នំខាវឡាងនឹង សម្រេចចិត្តចុះទៅថៃគេឲ្យចូលក្នុង

ជំរុំទី១ខាវឡាង ហើយជំរុំនឹងអ៊ំរស់នៅបានតែម៉ាខែទេ ក្រោមការគ្រប់គ្រងរបស់ថៃ។ ដល់រៀបចំបាន ថៃពាក់ព័ន្ធជាមួយខ្មែរក្រហម គ្មានឯងគ្រួសារអ្នកឯងមិនមាននៅប្រទេសទី៣ទេ អ្នកឯងធ្វើនិវត្តន៍ស្ម័គ្រចិត្តទៅវៀយួនវិញ។ កាលនោះគេនិយាយអីចឹង។ ក៏សុខចិត្តឡើងមកដល់ថ្មដា ទាហានថៃដឹកមកដាក់ខ្សែមនេះ កងទ័ពបេះវៃបុកៗរត់ទៀត អត់បាយទឹកទៀត ជំហានទី២ក៏រត់មកម្តងទៀត ក៏គេដឹកមកដាក់ជំរុំម៉ៃរ៉ូត ជំរុំ២០០១។ ហើយកន្លែងនឹងសុខដុមរមនា អត់មានភ័យបារម្ភអីទេ ហូបចុកគ្រប់គ្រាន់ទាំងអស់។ ខាងថៃក្រហម កាលនឹងវាខ្មែរក្រហមវាសហការណ៍គ្នា ប្រាប់ថាបងប្អូនត្រូវទៅវៀយួន... អត់មាននៅប្រទេសទី៣ទេ ដើម្បីរស់នៅទឹកដីរបស់ខ្លួនវិញ។ ដល់អីចឹងស្ម័គ្រចិត្តថា ដឹកខ្ញុំទៅខ្សែមទៅ ខ្ញុំសុខចិត្តទៅនៅនឹងដឹកជញ្ជូនឲ្យកងទ័ព ធ្វើម៉េចឲ្យទឹកដីរបស់ខ្ញុំនៅគង់វង្សវិញ។ មកដល់ខ្សែមនេះ ទប់យួនបានក៏គេដឹកយួនមកដាក់នៅខាវអ៊ីដាង។ អង្គការសហប្រជាជាតិនឹង ក៏សម្ភាសន៍ទៅប្រទេសទី៣ទៅមិនរួច ក៏ដឹកមកភូមិដូងនេះឯង។ គេឲ្យកសាងភូមិនឹង ដឹកជញ្ជូន ដែលគេឲ្យឈ្មោះថាកងដីរ លីអង្ករ លីគ្រាប់ សព្វបែបយ៉ាងនឹងឯង។ បញ្ហាជីវភាពអត់មានខ្វះខាតអីទេ ព្រោះអង្គការសហប្រជាជាតិគេដឹកអង្ករឲ្យក្នុងមួយខែក្នុងម្នាក់៣០គីឡូនៅតាមព្រំដែន។

ធានី : នៅឆ្នាំ៧០ ពូធ្វើពេទ្យ?

គុណា : បាទ!

ធានី : ពេទ្យនៅណា?

គុណា : ពេទ្យ បេះកាលឆ្នាំ៧០ យើងធ្វើរដ្ឋប្រហារលន់ នល់ គេធ្វើរដ្ឋប្រហារ កងទ័ពវៀតណាមផងខ្មែរក្រហមផង។ គេឲ្យយុវជន យុវនារីនៅតាមភូមិនឹងស្លៀកតែខោអាវខ្មៅទេ ម្នាក់ៗនៅផ្ទះអត់បានទេ។ តាមការបេះដឹងវប្បធម៌នឹង គេឲ្យខ្ញុំទៅរៀនពេទ្យ ទី១ជួយសង្គ្រោះនៅក្នុងសមរភូមិ ពេលប្រយុទ្ធបាក់ដៃ បាក់ជើងត្រូវធ្វើយ៉ាងម៉េច ចាក់ថ្នាំយ៉ាងម៉េច។ ខ្ញុំរៀនសូត្រនៅនឹងទៅ។ ដល់ឆ្នាំ៧៣-៧៤ ខ្ញុំឡើងដាច់មកខាងទ័ពតំបន់ ១១០ ១២០ កាលនឹងកងទ័ពតាស្រុះខ្ញុំធ្វើពេទ្យ។ ពេលប្រយុទ្ធបាក់ដៃបាក់ជើង ខ្ញុំសង្គ្រោះ...ចាក់ថ្នាំសង្គ្រោះទៅ។

ធានី : តាស្រុះនឹងនៅកងពលទីប៉ុន្មាន?

គុណា : កងពលទី១។

ធានី : កងពលទីរបស់តាអឿន?

គុណា : កងពលទី១ តាម៉ុក។

ធានី : តាស្រុះគាត់ជា?

គុណា : វរសេនាធំ។

ធានី ៖ ពូនៅអែបវរសេនាធំ?

គុណ ៖ ខ្ញុំ ពេទ្យវរសេនាធំ ។

ធានី ៖ ពូពេទ្យនៅក្នុងវរសេនាធំ?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ប្រធានពេទ្យនៅក្នុងវរសេនាធំ?

គុណ ៖ អត់មានប្រធានទេ ។

ធានី ៖ ពេទ្យតែមួយ?

គុណ ៖ បុគ្គលិកគេចាត់ចែងទាំងអស់ ។

ធានី ៖ ប៉ុន្មាននាក់បុគ្គលិករួម?

គុណ ៖ ហ៎! កាលនឹងច្រើនដែរ ព្រោះអីក្នុងម៉ាវរសេនាធំ មាន៣វរសេនាតូច ។

ធានី ៖ ពេទ្យពូប៉ុន្មាននាក់?

គុណ ៖ ពេទ្យខ្ញុំមាន៣ ។

ធានី ៖ ៣នាក់ ឬ៣វរៈដែរ?

គុណ ៖ ក្នុងម៉ាវរៈមានមួយ ។

ធានី ៖ ម៉ាវរៈសេនាតូចមានពេទ្យដែរ?

គុណ ៖ អត់ទេ ក្នុងម៉ាវរសេនាធំមានមួយ ។

ធានី ៖ មានតែមួយទេ?

គុណ ៖ ហ្នឹងហើយ ហើយ៣វរសេនាធំម៉ាកងពល ។ ដល់អីចឹងទៅ ខ្ញុំខាង១៧២ ។

ធានី ៖ វរសេនាធំ១៧២?

គុណ ៖ ហ្នឹងហើយ អូ!២០៣ ។ ហើយក្រៅពីនឹងទៀត ប៉ុនណាអី ខ្ញុំអត់ដឹងលេខគេប៉ុន្មាន ។

ធានី ៖ វរសេនាធំ៣០២?

គុណ ៖ ហ្នឹង៣០២ ។

ធានី ៖ តែពូម្នាក់ឯងទេ ម៉ាកងពលមានតែពេទ្យ៣នាក់?

គុណ ៖ ហ្នឹងហើយ៣នាក់ទេ សាខា គេចាត់ចែងវរសេនាតូចមួយទៀត ហើយវរសេនាតូចគេចាត់ចែងអនុសេនាធំមួយទៀត ។ កាលយើងទៅតាមអង្គភាព ។

ធានី ៖ តាម៉ុកគាត់ប្រធានកងពលទី?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ពូស្គាល់គាត់ដែរ?

គុណ ៖ តាម៉ុក ខ្ញុំធ្លាប់ទៅជួបគាត់ហៅទៅរៀនសូត្រ ។

ធានី ៖ រៀនសូត្រពេលណា?

គុណ ៖ វាពេលវេលាអត់ដឹង ប៉ុនកាលនឹងនៅបន្ទាយកន្ទែងរមាស ។

ធានី ៖ រមាសនៅកំពង់ឆ្នាំង?

គុណ ៖ ហ្នឹងហើយរមាសកំពង់ឆ្នាំង ខាងត្បូងកំពង់ឆ្នាំង ។

ធានី ៖ ភូមិអីគេ នៅស្រុករលាប្អៀរ?

គុណ ៖ នៅភូមិទឹកផុស ។ តាម៉ុកកាលនឹងបោះទីតាំងនៅនឹង ។

ធានី ៖ ឆ្នាំប៉ុន្មាន បានតាម៉ុកមក?

គុណ ៖ តាម៉ុកបើមែនទែន តាំងពីអើយមក តាំងពីឆ្នាំ៧០មក គាត់នៅនឹងរហូត ហើយកាលនឹងខាងទ័ពតំបន់នឹង ខាងកងទ័ពនារីឈ្មោះយាយ ម៉ែន ។

ធានី ៖ តាស្រុះ យាយម៉ែននឹងនៅជាមួយគ្នា?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ យាយម៉ែនខាងទ័ពនារី តាម៉ុកកងទ័ពបុរស?

គុណ ៖ បុរស ហ្នឹងហើយ គាត់ក្តាប់រួម ។

ធានី ៖ ចុះខាងណាបុរសម្នាក់ទៀត?

គុណ ៖ ម្នាក់ទៀតភ្លេចឈ្មោះហើយ ឈ្មោះអីនៅចុងៗមាត់ កាលនឹងខ្ញុំវាក្មេងទៅ ។

ធានី ៖ គេថាយាយម៉ែននឹងគាត់កាចណាស់?

គុណ ៖ អត់ទេ កុំចេះថាគាត់ ។

ធានី ៖ ម៉េចដែលគាត់ យាយម៉ែន?

គុណ ៖ មែនទែនទៅគាត់ស្លាប់ដោយសារធ្វើខ្លួនឯង ។ ឈ្មោះអីគេដែលកាន់ទ័ពតំបន់ខាងប្រុសយាយម៉ែន ខាងទ័ពនារី នៅចុងមាត់ៗវាភ្លេចអស់ហើយ ។ ព្រោះអីតាម៉ុកគាត់អ្នកក្តាប់រួម ម៉ាភូមិភាគនារតីគឺតាម៉ុកហើយ ចាត់ទុកជាកងពល ។ តែដល់វរសេនាតូច វរសេនាធំ វាមានសាខាទៀត ។ ហ៎! ឈ្មោះយឹម ភ្លេចហើយ តែបើស្រី ខ្ញុំចាំឈ្មោះថា យាយម៉ែន ក្នុងតំបន់ ។ ហើយវរសេនាតូច វរសេនាធំ ក្តាប់រួមទាំងអស់កងទ័ពនារីគឺឈ្មោះ យាយខុនមួយទៀត ។

ធានី ៖ យាយខុន យាយមែននារីដូចគ្នា ២នឹងក្តាប់នារីតែមួយ ឬមួយណាធំជាង?

គុណ ៖ អត់ទេ យាយខុននឹង គាត់ក្តាប់កងទ័ពនារីសម្រាប់ប្រយុទ្ធ ម៉ែននឹង ក្តាប់នារីក្នុងតំបន់ ឈ្មោះយឹមនឹងឯងក្តាប់ប្រុស ហើយតាម៉ុកក្នុងតំបន់ ។

ធានី ៖ យឹមខាងប្រុស?

គុណ ៈ ប្រុស ស្រីខាងយាយម៉ែន នឹងសម្រាប់តំបន់ៗ បើចុះពីតំបន់មកឈ្មោះខុនទៀត ។

ធានី ៈ ខាងប្រុសអ្នកណាគេ?

គុណ ៈ ឈ្មោះ យឹមនឹង ៗ តាម៉ុកគាត់ក្តាប់រួមក្នុងភូមិភាគនារតី ហើយចុះពីម៉ុកនឹងមកក្នុងតំបន់ ។

ធានី ៈ តំបន់មាន យាយម៉ែ ហើយនឹង?

គុណ ៈ តាយឹម ។

ធានី ៈ បន្ទាប់ខុននឹងបន្ទាប់?

គុណ ៈ ហ្នឹងហើយ កងទ័ពវរៈតូចនឹងឯង ។

ធានី ៈ កងវរៈធំ?

គុណ ៈ ឈ្មោះ យឹម ។

ធានី ៈ យឹមខាងទ័ពប្រុសក្នុងតំបន់ទេ?

គុណ ៈ ខាងទ័ពប្រុស ស្មើយាយខុនដែរ ។

ធានី ៈ យាយខុន និង តាយឹមស្មើគ្នា?

គុណ ៈ ស្មើគ្នា មួយខាងស្រី មួយខាងប្រុស ។

ធានី ៈ ចុះយាយម៉ែន?

គុណ ៈ យាយម៉ែនក្តាប់រួម ។

ធានី ៈ តាម៉ុកគាត់ក្តាប់រួមខាងបុរស យាយម៉ែនក្តាប់រួមដែរ ខាងនារី?

គុណ ៈ ចេះ ស្តាប់ព្រោះម៉ែននឹងក្នុងខេត្តកំពង់ឆ្នាំងគេហៅតំបន់៣១ តាម៉ុកនឹងភូមិភាគ ។

ធានី ៈ ភូមិភាគនារតី?

គុណ ៈ ហ្នឹងហើយ ភូមិភាគនារី ។ យាយម៉ែន ហើយយឹមនឹងគឺតំបន់ ។

ធានី ៈ ដល់ពេលខុន?

គុណ ៈ ខុនហ្នឹងវរៈទេ ។

ធានី ៈ វរៈរបស់ទូទៅ ឬវរៈតែស្រីទេ?

គុណ ៈ វរៈតែស្រីទេ ។ យឹម ហើយនឹងខុន គឺតំបន់៣១ ។

ធានី ៈ តំបន់៣១ បើគិតដល់ឥឡូវ ស្រុកបរិបូរ ឬស្រុកទឹកផុស?

គុណ ៈ ស្រុកតំបន់៣១ ស្រុកទឹកផុស បរិបូរ ភ្លេចអស់ កំពង់ត្រឡាចលើ កំពង់ត្រឡាចក្រោម ៣១ ទាំងអស់នៅនឹង ព្រោះម៉ានារតី ។ កំពង់ស្ពឺអាចចូលខ្លះដែរដឹង ។

ធានី ៈ ពូនៅខាងនារតី ឬនៅខាងបស្ចិមកាលនឹង?

គុណ ៈ ខ្ញុំនៅខាងនារតី ។ បាទ!នារតីខាងជើងផ្លូវជាតិលេខ៤ គេរាប់ចាប់នារតីទាំងអស់ ។

ធានី ៖ តែពូនៅខាងស្រុកទឹកផុស ស្រុកអីខាងនារតីដែរ?

គុណ ៖ នារតីដែរ ។

ធានី ៖ ហៅនារតី ឬហៅបស្ទឹម?

គុណ ៖ បស្ទឹមខាងតាកែវនោះវិញទេ ។

ធានី ៖ បើគិតតាមទិសនារតីខាងតាកែវ?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ដល់ពេលបស្ទឹមវាខាង?

គុណ ៖ អត់ទេ កាលនឹងកងទ័ពតាម៉ុកគ្រប់គ្រង គេបែងចែកតែពភូមិភាគទេ បូព៌ា នារតី បស្ទឹម ។ អត់ទេខាងខ្ញុំនៅខាងនារតី ខាងជើងផ្លូវជាតិលេខ៤មកទល់ខេត្តពោធិ៍សាត់នឹង គេហៅនារតី ហើយឡើងខាងនេះទន្លេសាបទៅកើតគេហៅបូព៌ាវិញទៅទល់ត្បូងឃ្មុំវាំង ។

ធានី ៖ ឆ្នាំប៉ុន្មានតាម៉ុកនៅក្តាប់ទ័ព ៧២ ៧៣ ៧៤ដែលគេបែងចែកភូមិភាគអីចឹង?

គុណ ៖ មិនមែនទេ គេក្តាប់តាំងពី៧០ ។

ធានី ៖ ពូដឹងតាម៉ុកនឹង ហៅឈ្មោះគាត់អី?

គុណ ៖ តាម៉ុកឈ្មោះ គាត់ពួកគេហៅតែម៉ុកៗនឹង ។

ធានី ៖ ហើយគាត់មានស្រុកកំណើតនៅណា?

គុណ ៖ នៅខេត្តតាកែវ កាលនឹងសាខារបស់តាម៉ុកខ្ញុំស្គាល់ ។

ធានី ៖ អ្នកណាគេ?

គុណ ៖ សាខារបស់គាត់មានភោគ ឆាយមួយទៀត ភោគ ឆាយ ហៅភោគ សំណាង ។

ធានី ៖ ភោគ ឆាយ ហៅភោគ សំណាង គាត់ជាអ្នកណាគេ?

គុណ ៖ ខ្ញុំអត់ដឹងដែរ ប៉ុនគាត់នឹងបានជារត់ទៅដោយសារតែ មិនដឹងម៉េចទេ ខ្ញុំមិនសូវដឹងដែរ ។

ធានី ៖ ភោគ ឆាយនឹង ជាសាខារបស់តាម៉ុក ហើយគាត់ធ្វើអីគេ បានសាខារបស់តាម៉ុក?

គុណ ៖ ដែលលេខា ។ ដល់អីចឹងមិនដឹងម៉េចបាត់ឈ្មោះ បាត់អីអស់រលាយអស់ ។

ធានី ៖ ពូដឹងថាក្រោយមកទៀត មែនទែនគាត់ធ្វើការងារអីគេ?

គុណ ៖ ភោគ ឆាយ លេខាតាម៉ុក បើមែនទែនខាងប្រកាសគណបក្សក្រោមការដឹកនាំរបស់ប៉ុលពត នឹង ។ ដល់អីចឹងបាត់រហូតទៅ មិនដឹងម៉េច ខ្ញុំមិនយល់ដែរ រឿងនឹង ។

ធានី ៖ បន្ទាប់មកទៀត ពូធ្វើទ័ពវរសេនាធំ៣០២នឹងហើយ ទៅណាទៀត?

គុណ ៖ ដល់៧៩ យួនចូលមករលាយអស់ទៅ ។

ធានី ៖ ចុះមុននឹង ៧៣ ៧៤ ពូថាធ្វើទ័ព?

គុណ ៖ កងចល័ត?

ធានី ៖ អត់ទេ ៧៣ ៧៤ ពូធ្វើពេទ្យនៅប្រចាំ?

គុណ ៖ អូ! ហ្នឹងហើយ ៧៣ ៧៤ ខ្ញុំមកធ្វើពេទ្យនៅកោះកុង ហ្នឹងហើយប្រចាំវរសេនាធំកងពលទី ១ ។ ដល់រួចពីនឹងមក បាន៧៩យួនចូលមកបានខ្ញុំរសាត់អណ្តែតមក ។ មុននឹង៧៩នេះ នៅឆ្នាំ៧០ខ្ញុំពង្រាយរៀនសូត្រខាងពេទ្យសង្គ្រោះនឹងមកទល់៧៩បានគេឲ្យមកនៅខាងកោះកុង ។ ដល់ចេញកោះកុងយួន៧៩ចូលមក ក៏ខ្ញុំធ្លាក់ខ្លួនមកជា ។

ធានី ៖ កងដឹកជញ្ជូន?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ពូធ្វើពេទ្យនឹងរៀនប៉ុន្មានថ្ងៃ ហើយរៀននៅកន្លែងណាទៅ?

គុណ ៖ រៀនច្រើនដែរនឹង កាលនឹងខ្ញុំនៅរៀន កាលវៀតណាមយើងនៅត្រូវគ្នា ខ្ញុំរៀនអស់រយៈពេល៣ខែ នៅស៊ឹងស្នួត ។

ធានី ៖ ស៊ឹងស្នួតនៅ?

គុណ ៖ ស៊ឹងស្នួតនៅភូមិគាចេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងដដែល ។

ធានី ៖ រៀននៅឃុំ?

គុណ ៖ ហ្នឹងហើយ ពេទ្យសង្គ្រោះ ។

ធានី ៖ នៅឆ្នាំប៉ុន្មានពូរៀនពេទ្យ?

គុណ ៖ នៅឆ្នាំ៧១ ខ្ទង់៧១នៅស៊ឹងស្នួត ។

ធានី ៖ អ្នកណាគេអ្នកបង្រៀនពូ?

គុណ ៖ ឈ្មោះ ហ៊ូ ។

ធានី ៖ ហ៊ូ គាត់មកពីណា?

គុណ ៖ ហ៊ូ គាត់នៅស្រុកនឹងដែរ ពេទ្យប្រចាំស្រុកបណ្តោយ ហ៊ូនឹងនៅជាប់ខ្លះគេហៅតាហួង ខ្លះហៅអួង ។

ធានី ៖ ហួងហៅអីគេ?

គុណ ៖ ហួងហៅអួង ។

ធានី ៖ អួងនឹងគាត់ងារអីគេ?

គុណ ៖ ខាងអភិបាលស្រុក ។

ធានី ៖ អភិបាកស្រុកអីគេ?

គុណ ៖ ស្រុកកំពង់ត្រឡាច គេហៅគណៈស្រុកពីដើម ។

ធានី ៖ កាលនឹងគេហៅស្រុកប៉ុន្មាន?

គុណា ៖ ស្រុក១៨ នឹងក្រោមផ្លូវជាតិលេខ៥ មកទល់ទន្លេ ។ ខាងលើទៅគេហៅស្រុក១២នឹងមិនដឹងជាអ្នកណាចៅហ្វាយស្រុក ដឹងថាក្រោមផ្លូវជាតិលេខ៥មកទល់ទន្លេនឹង គេហៅស្រុក១៨ ។

ធានី ៖ ចុះពូមានបានចូលប្រយុទ្ធនៅភ្នំពេញនឹងគេទេ?

គុណា ៖ មាន...ចង់ងាប់ គ្រាប់ផ្លោង ឡានហោះក៏មាន ។

ធានី ៖ ប្រយុទ្ធកាលឆ្នាំ៧៥ ពូមានប្រយុទ្ធនឹងគេទេ?

គុណា ៖ ហ្នឹងហើយ ថាអីគ្មានអីទេ ហៅកងដឹកជញ្ជូនបានឲ្យកងទ័ពនឹងឯង គ្មានធ្វើអី ។

ធានី ៖ តែពូថាធ្វើពេទ្យ?

គុណា ៖ ធ្វើពេទ្យ ប៉ុននឹងក៏យកបាយឲ្យគេផង ។

ធានី ៖ ទៅដល់ភ្នំពេញ?

គុណា ៖ ខ្ញុំកាល៧០នឹងទៅដល់ភ្នំពេញ ។

ធានី ៖ ៧០ ឬ៧៥?

គុណា ៖ ហ៊ឺ! ៧៥ ។

ធានី ៖ ៧៥ទៅដល់ភ្នំពេញដែរ?

គុណា ៖ បាទ!

ធានី ៖ នៅម្តុំណាកាល៧៥?

គុណា ៖ ខ្ញុំនៅម៉ាផ្លូវវត្តទួលទំពូងម្តុំស្ទឹងមានជ័យ ។ យកបាយឲ្យគេផង មើលថាកងទ័ពរបួសអីសង្គ្រោះគេ ។

ធានី ៖ ព្យាបាលផង យកបាយឲ្យគេផង?

គុណា ៖ ហ្នឹង ។

ធានី ៖ បន្ទាប់មកទៀតម៉េចទៀត ពេលដល់៧៥?

គុណា ៖ ដល់រំដោះហើយ គឺគេបញ្ជូនខ្ញុំទៅជាមួយកងយោធាទៅ កសាងផ្លូវជាតិលេខ៣ខាងតាកែវជួសជុលផ្លូវគមនាគមន៍ ។ រួចពីនឹងមក យើងជួសជុលអីហើយបានគេឲ្យខ្ញុំមកនៅកំបូលបែកចាន អង្គស្នួល នៅជាមួយ ។ និយាយរួមទៅតួនាទីខ្ញុំជាពេទ្យរហូត ។

ធានី ៖ ពេលពូជួសជុលផ្លូវនៅពេទ្យដែរ?

គុណា ៖ ហ្នឹងហើយនៅពេទ្យរហូត ។

ធានី ៖ ពេទ្យអីគេ?

គុណា ៖ ពេទ្យកងទ័ព ។

ធានី ៖ គេហៅពេទ្យអីគេ ដែលគេហៅកងទ័ពអីគេ ដែលមកជួសជុលផ្លូវ?

គុណ ៖ កងទ័ពនឹងវ-១៦ ។

ធានី ៖ វរៈ១៦?

គុណ ៖ វ-១៦ តែវរៈ១២៧ ។

ធានី ៖ កងពលទីប៉ុន្មាន?

គុណ ៖ កងពលទី១ដដែល វ-នឹងវរសេនាធំ ។

ធានី ៖ វរសេនាធំ?

គុណ ៖ បាទ!

ធានី ៖ ចុះ១២៧នឹង?

គុណ ៖ ១២៧នឹង វរសេនាតូច ។

ធានី ៖ តែខុសកងមុន?

គុណ ៖ ៣០២នឹងតំបន់ ។ ដល់ពេលគេបំពេញសិទ្ធិអីមកទៅជាវរ១២៧វិញ ។

ធានី ៖ តំបន់៣០២?

គុណ ៖ តំបន់គឺលេខក្នុងខេត្ត គឺឲ្យកងទ័ពនឹងពីដើមមានកងទ័ពស្រុក កងទ័ពតំបន់ កងទ័ពភូមិភាគ ។

ធានី ៖ ពូនៅក្នុងកងទ័ពតំបន់៣០២?

គុណ ៖ ៣០២ ដល់ឡើងភូមិភាគ១២៧នេះ ។

ធានី ៖ ចុះនៅពេលនៅពេទ្យនេះ កងទ័ព១៦ វរសេនាធំ១២៧ដែរ?

គុណ ៖ បាទ! ហ្នឹងហើយ ។

ធានី ៖ តែនៅកងពលទី១ដដែលអត់ទាន់រំសាយទេ?

គុណ ៖ អត់ទាន់រំសាយទេ នៅដដែល ។

ធានី ៖ តែតាម៉ុកនៅដឹកនាំដដែល?

គុណ ៖ ដដែល ។

ធានី ៖ ពូនៅអែបតាស្រុះ?

គុណ ៖ កាលនឹងកាលនៅជាសម័យប្រជាជាតិ ខ្ញុំនៅជាមួយតាស្រុះ ។

ធានី ៖ ដល់ក្រោយមក?

គុណ ៖ ក្រោយមក កងទ័ពចេះរីកឡើង គេបែកទៅមុខតាមលំដាប់ ។

ធានី ៖ ពូនៅណាវិញ?

គុណ ៖ ខ្ញុំនៅកំពង់ឆ្នាំងដដែល៣០២ ចេញពីតាស្រុះមក ។

ធានី :  ពូជួសជុលផ្លូវជាតិលេខ៣ កងពលទី១ តាម៉ុកដដែល?

គុណ :  តាម៉ុក ។

ធានី :  ហើយអ្នកណាគេគ្រប់គ្រងពីលើពូ តាម៉ុកនឹង ឬអ្នកណាផ្សេង?

គុណ :  គ្រប់គ្រងលើខ្ញុំឈ្មោះផល រស្មីមួយទៀត ។

ធានី :  រស្មីស្រី?

គុណ :  រស្មីប្រុសស្នងបញ្ជា ។

ធានី :  ស្នងបញ្ជាម៉េច?

គុណ :  ស្នងចង់និយាយថាអ្នកនយោបាយ ។

ធានី :  មួយណាអ្នកបញ្ជា មួយណា?

គុណ :  នែក! រស្មីបញ្ជាការ ។

ធានី :  គាត់ធំ?

គុណ :  អត់ទេ រស្មីនឹងក្រោមការដឹកនាំរបស់ផលទេ ផលនឹងស្នងអ្នកនយោបាយ ។

ធានី :  ផលនឹង ធំជាងរស្មី?

គុណ :  ហ្នឹងហើយផលនឹងធំជាងរស្មី ។

ធានី :  តែផលនឹងខាងនយោបាយទេ រស្មីជាអ្នកបញ្ជា?

គុណ :  បញ្ជាទាំងអស់ខាងអីៗច្រើន ។

ធានី :  អ្នកនយោបាយធំជាងអ្នកបញ្ជា?

គុណ :  ធំជាង ។

ធានី :  ពូនៅជួសជុលផ្លូវ អត់ធ្វើទេ គ្រាន់ជួយព្យាបាល?

គុណ :  ខ្ញុំនៅជួសជុលផល ព្យាបាលបងប្អូនកងទ័ពឈឺគ្រុនផង ។

ធានី :  ម៉េចទៀត ៧៥ ធ្វើផ្លូវ ពូថានៅបែកចាន?

គុណ :  ដល់ចប់សព្វគ្រប់ហើយ គេឲ្យខ្ញុំមកនៅបន្ទាយកន្ទោកជំពូវន្តនេះ ធ្វើស្រែចំការហើយកសាងប្រទេស ។

ធានី :  លែងធ្វើពេទ្យហើយ?

គុណ :  នៅដដែលនឹង គេធ្វើក៏ធ្វើ នៅកសាងប្រទេសចូលរួមគ្នាទាំងអស់ ។

ធានី :  កាលពូធ្វើពេទ្យនៅកន្លែងណា នៅកន្ទោកនឹង?

គុណ :  ហ្នឹងហើយ ខ្ញុំនៅនឹងឯង ធ្វើតាំងពី៧០មក រៀនពីវៀតណាម ។

ធានី :  ពេទ្យនឹងគេហៅពេទ្យអីគេ?

គុណ ៖ ពេទ្យយោធា ឲ្យតែអន្តភាពយោធាត្រូវតែមើល ត្រូវតែផ្សព្វផ្សាយទាំងអស់ ។

ធានី ៖ ពូមកជាមួយអន្តភាពដដែល?

គុណ ៖ បាទ!

ធានី ៖ អន្តភាពដដែលវរសេនាធំ១៦?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ វរសេនាតូច១២៧?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ កងពលទី១?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយប្រធានតាម៉ុកដដែល?

គុណ ៖ ដដែល ។

ធានី ៖ ហើយមកធ្វើស្រែនៅកន្ទោក ហើយម៉េចទៀត?

គុណ ៖ ដល់ក្រោយពីកន្ទោកមកសភាពការណ៍ថៃនៅកោះកុង គេបញ្ជូនកងពលទី១មកមានវរសេនាតូច១២១ ។ អូ! ១២៧ អន្តភាពខ្ញុំនឹង ព្រោះថៃវាចង់ឈ្លានពានយើង កាលយើងមានភាពច្របូកច្របល់ ។ វរសេនាតូចវ-១៥មួយទៀត ។

ធានី ៖ មាន២?

គុណ ៖ មាន២វរសេនាតូច មកដល់កោះកុង ដងទង់នេះ ហើយខ្ញុំមកតាមគេទាំងអស់នឹងឯង ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំមក?

គុណ ៖ តាគឿនៗ ។

ធានី ៖ តាគឿនអ្នកដឹកនាំមក?

គុណ ៖ តាគឿនកងពលតូចទី១ដែរ ។

ធានី ៖ ពូថាមក២វរៈ?

គុណ ៖ ហ្នឹងហើយមក២វរៈ ខ្ញុំមកតាម១២៧នឹង គឺក្នុងពេទ្យ១២៧ តែវ-១៥អត់ស្គាល់មិនដឹងពេទ្យគេឈ្មោះអីទេ ។ គេបញ្ជូនមកក្នុងករណីដែល ពេលយើងរំដោះហើយថៃ គេច្របូកច្របល់តាមកោះតាមអី គេយកមក២វរៈ ១២៧, វ-១៥ ។

ធានី ៖ វ-១៥ វរសេនាតូច?

គុណ ៖ វ គេហៅវរសេនាតូច ។

ធានី ៖ ចុះវរសេនាធំគេហៅអី?

គុណ ៖ វរសេនាធំ១៦ ។

ធានី ៖ ចុះពូមិញថាវគេហៅវរសេនាតូច?

គុណ ៖ ហាំ! អត់ទេ វ វរៈសេនាធំ ។

ធានី ៖ វរសេនាធំ១៥មួយ?

គុណ ៖ ១២៧មួយ អានឹងអាតូចៗ វ-១៦រួម ។ ដូច្នេះក្នុងម៉ាកងពលតូចក្នុងម៉ាភូមិភាគនារតីនឹងវា មានពាកងពលតូច ។ វ-១៥ វ-១៦ វ-១៧ ។ ដល់ខ្ញុំនៅក្នុងវរសេនាធំ វ-១៦នឹង គឺ កង១២៧ ។

ធានី ៖ កងតូច?

គុណ ៖ ហ្នឹងហើយ ។ ហើយវ-១៥ វរសេនាធំ ។

ធានី ៖ តែមួយ?

គុណ ៖ អត់ទេ ខុសគ្នា ។

ធានី ៖ គេមកពាវរៈផ្សេងៗគ្នា?

គុណ ៖ ម៉ាកងពលមានពាវរសេនាធំ វ-១៦ វ-១៧ វ-១៥ ។ អំរស់នៅវ-១៦ វរសេនាធំ តែ វរសេនាតូច១២៧ ។

ធានី ៖ ចុះផ្សេង?

គុណ ៖ ដល់វ-១៥នេះ វាយូរហើយចង់ភ្លេចអស់ហើយ ។

ធានី ៖ មកតែ២វរនឹង?

គុណ ៖ ហ្នឹងហើយមក២វរៈ ។

ធានី ៖ អ្នកដឹកនាំរបស់ពូគឺតាគឿង?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ តាសឿន ឬតាគឿង?

គុណ ៖ តាគឿង ។ ចង់ភ្លេចអស់ហើយ ស្លាប់អស់ហើយ ។

ធានី ៖ កាលពេលពូមកៗកោះកុងនឹង មកការពារព្រំដែន?

គុណ ៖ ហ្នឹងហើយ គេឲ្យមកតាមកងទ័ពការពារព្រំដែន ។

ធានី ៖ ពូចាំទេ អ្នកណាគេ អ្នកឲ្យមក?

គុណ ៖ បទបញ្ជាពីថ្នាក់លើ ។

ធានី ៖ ចាំឈ្មោះគាត់?

គុណ ៖ មិនដឹងឈ្មោះអី បើខាងលើហើយ អង្គការលើហើយ ។

ធានី ៖ ហើយឆ្នាំប៉ុន្មានពូមកកោះកុង?

គុណ ៖ ៧៦ ។

ធានី ៖ ពូធ្វើពេទ្យនឹង ពូអត់បានរៀននៅភ្នំពេញទេ ពេទ្យតាមកងទ័ពរហូត?

គុណ ៖ ហ្នឹងហើយ ពេទ្យកងទ័ពហើយ ។

ធានី ៖ ពូដែលស្គាល់ជួន ជឿនទេ?

គុណ ៖ គាជួន ជឿន ក៏ធ្លាប់បង្រៀន ។

ធានី ៖ គាជួន ជឿននឹងបង្រៀនពូដែរ?

គុណ ៖ បង្រៀន ។

ធានី ៖ បង្រៀនពេលណា?

គុណ ៖ ពេលណាដែលចប់សង្គ្រាមហើយ និយាយពីការសង្គ្រោះ និយាយពីព្យាបាលជម្ងឺប្រភេទជម្ងឺ វិភាគជម្ងឺ ។

ធានី ៖ ពូរៀននៅណា?

គុណ ៖ ខ្ញុំរៀននៅភូមិដូងនេះ ប៉ុនរយៈពេលម៉ោអាទិត្យ ព្រោះពេលវាខ្លី ។

ធានី ៖ នៅណា?

គុណ ៖ ភូមិដូងយើង ។

ធានី ៖ ឆ្នាំប៉ុន្មាន?

គុណ ៖ ហ៎! ភ្លេចឆ្នាំហើយ ។

ធានី ៖ ៧៩ហើយ?

គុណ ៖ ៧៩ ៨០ប៉ុន្មាន ។

ធានី ៖ ពេលសម័យ៣ឆ្នាំ ពូអត់បានជួបគាជួន ជឿនទេ?

គុណ ៖ អត់ទេ ខ្ញុំរៀននៅហានណូយ ឈ្មោះ ង៉ោល ហ៊ូ ។

ធានី ៖ ង៉ោល ហ៊ូពេទ្យវៀតណាម?

គុណ ៖ ហ្នឹងពេទ្យមកពីហានណូយ អានឹងគេបង្រៀនសង្គ្រោះ មិនមែនរៀនព្យាបាលទេ ។ ដល់ពេលខ្ញុំមកកោះកុងនេះ លោកហ៊ានមួយទៀត មកបង្រៀនខ្ញុំពីរឿងព្យាបាលជម្ងឺ ពិនិត្យជម្ងឺ ពិនិត្យមេរោគ ។ គាជួន ជឿនដល់ចុងបំផុត ដល់យើងរួចខ្លួនមានទីតាំងតាមព្រំដែននឹង ទប់ទល់ជាមួយវៀតណាម គាត់មកបង្រៀនពីរឿងព្យាបាលជម្ងឺ ព្រោះអីតាមព្រំដែនមានជម្ងឺច្រើន ឲ្យខ្ញុំរៀនពីរឿងព្យាបាលជម្ងឺ វិភាគជម្ងឺទៅ ។ ប៉ុនទីតាំងគាត់នៅកំរៀងនោះ ។ កូនសិស្សគាត់រាល់ថ្ងៃអ្នកធ្វើពេទ្យ ។

ធានី ៖ ពូឥឡូវឈប់ធ្វើពេទ្យហើយ?

គុណ ៖ បញ្ហារឿងពេទ្យនឹង វាសំខាន់ញាបាលរឿងស្មារតី ផ្នែកសុខភាព ដៃក៏ញ័រចាក់ថ្នាំគេមិនកើត ទៅអត់រួច ។

ធានី ៖ អីចឹងឈប់ទៅ?

គុណ ៖ ឈប់ទៅ ។

ធានី ៖ កាលមុនពូធ្វើពេទ្យ?

គុណ ៖ ខ្ញុំធ្វើពេទ្យ ។

ធានី ៖ រហូតដល់ពេលណាបានពូឈប់ធ្វើ?

គុណ ៖ ខ្ញុំភ្លេចពេលវេលា៧៩បញ្ចប់ស្តាពរបណ្តោយ ។

ធានី ៖ ចុះពូថារៀនជាមួយដួន ដឿន?

គុណ ៖ ៧៩ ខ្ញុំរៀនមុន៧៩ ។

ធានី ៖ រៀននៅណា?

គុណ ៖ ខ្ញុំរៀននៅភូមិដូងនេះ ។

ធានី ៖ ពូមកដល់ម៉ាឡៃពេលណា?

គុណ ៖ ខ្ញុំមកដល់ម៉ាឡៃ៨០ប៉ុន្មានទេ ៨៣ ។

ធានី ៖ ៨៣មកដល់ម៉ាឡៃ?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយរៀនជាមួយដួន ដឿន ៨៣នឹងដែរ?

គុណ ៖ ក្នុងកំឡុង៨៣ ៨៤ ៨៥នឹង ។

ធានី ៖ រៀនជាមួយគាត់?

គុណ ៖ ហ្នឹងឯងរៀនជាមួយគាត់ ។ ខ្ញុំវាភ្លេចដែរ ។

ធានី ៖ កាលនៅ៧៦ ពូនៅកោះកុងនៅធ្វើពេទ្យវរសេនាតូច១២៧រហូត?

គុណ ៖ បាទ! ដល់វៀតណាមវៃ៧៩មក បានរត់ខ្ចាយបណ្តោយ ។

ធានី ៖ ពូដឹងប្រធានវរសេនាតូចអ្នកណាគេ?

គុណ ៖ ប្រធានវរសេនាតូចឈ្មោះ គាត ។

ធានី ៖ ចុះតាគឿននឹងអ្នកណាគេ?

គុណ ៖ តាគឿនកងពល ។

ធានី ៖ កងពលទីប៉ុន្មាន?

គុណ : កងពលទី១នោះ ។

ធានី : ចុះតាម៉ុកនោះ?

គុណ : តាម៉ុកនឹងខាងនារតី កាលពីដើមកាលនៅវិសម័យប្រជាជាតិគាត់ប្រធានកងពល ដល់ពេលរំដោះអីហើយ គាត់ឡើងគណៈភូមិភាគ ។ ឲ្យតាគៀងធ្វើប្រធានកងពលម្តង ។ ដល់គាតនឹងប្រធានវរសេនាតូច ហើយបញ្ជាការឈ្មោះ ឈុតមួយទៀត ។

ធានី : ២នាក់នឹងមួយណាធំ?

គុណ : គាតនឹង វរសេនាតូចដែរ គាតស្នង ឈុតនឹងបញ្ជា ។

ធានី : ស្នងអីគេ?

គុណ : ស្នងគេហៅអ្នកនយោបាយ ។

ធានី : ស្នងការ?

គុណ : ហ្នឹងហើយស្នងការនយោបាយនឹង ។

ធានី : គាត បញ្ជាការ?

គុណ : ហ្នឹងហើយមេបញ្ជាការនឹងទៅ ។

ធានី : អីឈុតៗបញ្ជាការ?

គុណ : ឈុត ។

ធានី : ពូនៅពេទ្យនឹងដដែល នៅម្នាក់ឯង ឬមានពេទ្យនារីៗនៅជួយធ្វើ?

គុណ : គ្នាច្រើនដែរ ប៉ុនភ្លេចគ្នាអស់ហើយ ។

ធានី : កាលនឹងពូធ្វើជាអីពេទ្យ ប្រធានពេទ្យ?

គុណ : ខ្ញុំមិនជាអីទេ ប៉ុនអ្នកឯកទេសមួយវិធីវះកាត់ ។

ធានី : ពូចេះវះកាត់ដែរ?

គុណ : វះតូច វះធំខ្ញុំចេះទាំងអស់ ។

ធានី : ពូប្រធានវះកាត់?

គុណ : អត់ទេ ប្រធាន ប៉ុន្តែក្នុងសាខាគេមាន៣នាក់ ។

ធានី : ៣នាក់អ្នកណាខ្លះ?

គុណ : ឈ្មោះ បូរ៉ាមួយប្រធាន វឿន មួយអនុប្រធាន ហើយខ្ញុំសមាជិក ។ ប៉ុនវិធីវះកាត់នៅគ្រោះថ្នាក់នៅព្រំដែនដែលប្រយុទ្ធមានបញ្ហាតូចធំអីមាន៣នឹងហើយពិគ្រោះគ្នាណា ។

ធានី : បូរ៉ានឹងផ្នែកអីទេ?

គុណ : បូរ៉ានឹងឯកទេស ។

ធានី ៖ ឯកទេសដូចពូដែរ?

គុណ ៖ ដូចគ្នា ប៉ុនគ្រាន់ថាគេប្រធានគ្រប់គ្រង រឿននឹងអនុប្រធាន ខ្ញុំសមាជិក ។ មុននឹងចូលដល់វិធីវះកាត់អីមួយ យើងឃើញថា ។

ធានី ៖ ៣នាក់?

គុណ ៖ បាទ! នៅកោះកុងនឹង ។

ធានី ៖ ប្រចាំពេទ្យនៅនឹង?

គុណ ៖ ប្រចាំនៅនឹងដល់៧៩ ។

ធានី ៖ ហ្នឹងគេហៅពេទ្យអីគេ?

គុណ ៖ ៣នាក់គេហៅពេទ្យយោធានឹងឯង អត់មានដោះស្រាយ ។

ធានី ៖ ពូដឹងថាមានកងពល១៦៤?

គុណ ៖ មាន តែអានឹងគេអត់មកពាក់ព័ន្ធជាមួយយើងទេ ។

ធានី ៖ កងពល១៦៤ យោធាដែរ?

គុណ ៖ យោធា ប៉ុន្តែខ្ញុំស្គាល់ខ្លះ ព្រោះកាលនឹងខ្ញុំនិយាយឲ្យវែងបន្តិច ។ មុនកងពលទី១មាន២វរៈទៅនៅកោះកុង ១៦៤គេទៅនៅមុន ១៦៤ខាងជើងទឹក ។ កងពលទី១ វ-១៦ និង វ-១៧ទៅនៅនឹង បាន១៦៤ គេឡើងទៅកំពង់សោមវិញ ។

ធានី ៖ គេឈប់នៅនឹង?

គុណ ៖ គេឈប់នៅនឹង ព្រោះកងពលទី១មកកាន់កាប់វិញ ។ ១៦៤គេទៅនៅនឹង កូនចៅអ្នកគេដើរទាក់ក្របីអីរបស់ប្រជាជនរស់នៅនឹង... ដល់១៦៤ ដល់ពេលមានគ្រោះថ្នាក់អីក៏មកឲ្យពេទ្យខ្ញុំដែរ ។ ទីតាំងគេនៅកំពង់សោម ទីតាំងខ្ញុំនៅត្រឹមដងទង់ កូនចៅគេមកធ្វើការងារ គេមកមើលកន្លែងទាក់ក្របីទាក់អីសម្រាប់យកមកបម្រើការងារក្នុងអង្គភាពគេនឹង ។ ថ្ងៃមួយភ្នំគោកទួលគគីរ ឈ្មោះ ឈឿន យោធា ហើយនិងមួយទៀតឈ្មោះអីខ្ញុំអត់ស្គាល់ ។ ប្រកភ្នំទួលគគីរ វាដាក់អន្ទាក់សម្រាប់ទាក់ក្របីប្រជាជនរត់ចូលថៃ វាទាក់យកមកដើម្បីធ្វើការងារក្នុងស្រុកភូមិយើង ។ ដល់ឈ្មោះ ឈឿននឹង ដាក់អន្ទាក់ ក្របីនឹងជាប់អន្ទាក់ខ្លាវាអូសយកទៅមានតែ២នាក់ទេ ទៅមើលអន្ទាក់២នាក់ បើថាជាប់ហើយនាំគ្នាទៅ...យកទៅឲ្យកងពលដើម្បីចែកចាយទៅតាមសហករណ៍ឲ្យប្រជាជនតាមសហករណ៍ ។ ថ្ងៃនឹង ដឹងថៃដន្យអីឈ្មោះឈឿននឹង ខ្ញុំស្គាល់តែមួយទេ ប្រហែលម៉ោង១២យប់ខ្ញុំកំពុងដេកៗគេមកដាស់ ពេទ្យជួយសង្គ្រោះខ្ញុំផង ព្រោះខ្ញុំខ្លាខះ ។ ដល់ឈ្មោះឈឿន បក(ស្បែក)អស់រលីងមកដល់នេះ ឃើញថាឈាមខ្លា ដាច់អន្ទាក់ខ្លាទៅហើយ ដើរៗទៅខ្លាមក ស្រាប់តែឈឿននឹងកំរើកអីមិនបាន អា

ម្នាក់ទៀតមានគ្រាប់បែកម៉ាគ្រាប់ ហើយកាំភ្លើងម៉ាដើម ។ ដោះស្រាយម៉េចទេ កំរើកទះៗ ហើយខ្លានឹងមួយកំពុងស៊ីក្របីនឹង នៅទួលគគីរ ។ ម្នាក់នឹងមិនដឹងគិតមធ្យោបាយម៉េចទេ ទៅរាយអន្ទាក់តែ២នាក់ ទាក់ក្របីជូនអគ្គភាពដើម្បីចែកតាមសហករណ៍ប្រើប្រាស់ ។ ដល់អីចឹងគ្រាប់បែកម៉ាគ្រាប់ កាំភ្លើងម៉ាដើម ឡើងដើមព្រហូត បើបោកគ្រាប់បែកទៅគ្រោះថ្នាក់គ្នាឯង បើបាញ់មិនដឹងបាញ់ម៉េច ។ ដល់អីចឹងបេះផ្លែព្រហូតបោស អានោះប្រុចមកដល់គ្រប់ផ្លែព្រហូត ។ ដល់អីចឹងវាមានឱកាសហើយកាចគ្រាប់បែកបោះ ខ្លាបាក់ជើងដៃ ដឹកឲ្យចិន ។ សែងគ្នាម៉ាវរសេនាតូច ខ្លានឹងអូសពីទួលគគីរ ខ្លានឹងធំណាស់ ។

ធានី ៈ វាងាប់ឬនៅ?

គុណ ៈ ងាប់ហើយ ចុះគ្រាប់បែកបាញ់ថែម អាឈឿនងើបមកម៉ោង១២យប់យកមក ។ ដល់ម៉ោង១២យប់ យកមកឲ្យខ្ញុំដេរស្បែកក្បាលអស់រលីង ។

ធានី ៈ អត់អីទេ គ្រាន់របក?

គុណ ៈ ហ្នឹងហើយអត់អីទេ រស់ ។ ៧៩យួនចូលមកទៀត អាឈឿននឹងមានប្រពន្ធ២ទៀត ។ វារត់មកចូលថៃទាំងអស់គ្នា បែកគ្នាទៅ ។

ធានី ៈ កាលពេលគេចាប់ខ្លាបាន គេយកទៅឲ្យចិន ម៉េចបានពូដឹង?

គុណ ៈ ដឹកប៉េសេអេសយកទៅ ។

ធានី ៈ យកមកកំពង់សោម?

គុណ ៈ ហ្នឹងយកឲ្យចិនបណ្ដោយ មិនដឹងគេយកធ្វើអី ខ្ញុំអត់ដឹងទេ រឿងនឹងគ្រាន់ដឹងអីចឹង ។

ធានី ៈ ធំដែរ ដឹងប៉ុន្មានម៉ែត្រ?

គុណ ៈ មែនទែនទៅមិនតូចទេ គ្រាន់ដើរទៅជិតធំស្អុយចង់ងាប់ចង្អូមវាយកមកដាក់ដៃដឹកប៉េសេអេសនៅមុខដំណាក់សម្ដេចនៅកោះកុង ក្រុងដងទង់ ។

ធានី ៈ កោះកុងមានដំណាក់ស្ដេចមួយដែរ?

គុណ ៈ មានទាំងអស់ មានដំណាក់ស្ដេច ផ្ទះលន់ នល់... ទាំងអស់ នឹងទល់មុខមណ្ឌលសីមា ចេតិយឃុនឆាងឃុនផែន ។ ដល់គេយកមក គេយកមកដាក់នៅដៃប៉េសេអេសនឹងបាន ប៉េសេអេសដឹកយកទៅកំពង់សោម យកឲ្យចិនៗគេមកថត ។

ធានី ៈ ប៉េសេអេសធំដែរ ដឹកខ្លាបានដែរ?

គុណ ៈ ប៉េសេអេសធំដែរតើ គេមិនមែនដឹកនៅប៉េសេអេសទេ គេមានអានេះមួយទៀតដាក់ពីក្រោយ ។ សែងគ្នាម៉ាវរសេនាតូច ខំអូសតាំងពីទួលគគីរ មិនតិចគីឡូទេ ចូល៧-៨គីឡូ ។

ធានី ៈ ទួលគគីរនៅណា?

គុណ ៖ ទួលគគីរនៅកោះកុង នៅដងទង់ នៅខាងលើនឹង...។

ធានី ៖ ហួសតាតែ?

គុណ ៖ ...តាតែភូមិដូង ហួសមកនេះទៀត ទួលគគីរឆ្លងស្ទឹងទំនប់តាតែមកមិនភ្នំទួលគគីរ ចេញពីទួលគគីរមកព្រែកស្វាយ ហើយឡើងពីទួលគគីរទៅហៅស្រម៉ាលើស្រម៉ាក្រោម ចុះ៧៩យួនវៃមកបានខ្ញុំរត់ចេញមកនឹង ។

ធានី ៖ ពូធ្លាប់ឃើញនេសាទថៃខស្សាហ៍ចូលមកដល់?

គុណ ៖ និយាយឲ្យត្រង់ទៅចុះ ខ្ញុំអត់កុហក់ទេ កាលនឹងយើងមានទូកម៉ាគ្រឿង យើងមានព្រឹត្តិការណ៍ថៃវាមកអុកឡុកយើងទូកយើងប្រើអត់ខ្វះទេ...។

ធានី ៖ តាំងពីទូកមួយរហូតដល់ទូកច្រើន?

គុណ ៖ ហ្នឹងហើយ យើងមាន ៣០សេសមួយ ក្រៅពីនឹងថៃវាចូលមក...យើងចាប់យក ។

ធានី ៖ ខាងយើងចាប់យក?

គុណ ៖ ចាប់យក ។

ធានី ៖ ហើយវារករឿងដែរ?

គុណ ៖ វាចេះរកៗទៅ វាឆ្លានពានទឹកដីយើង ហើយមេបញ្ជាការដើងទឹកឈ្មោះតាញាយ ។

ធានី ៖ តាញាយនឹងកងពល១៦៤?

គុណ ៖ កងពលទី១ដែរ ប៉ុនតាត់ខាងដើងទឹក ។

ធានី ៖ មានកងពលទី១ មានដើងទឹកទៀត?

គុណ ៖ មានដើងទឹក មានដើងគោក១២៧ខាងដើងគោក ដែលតាញាយខាងដើងទឹកមិនដឹងលេខប៉ុន្មានទេភ្លេចហើយ ។

ធានី ៖ តែវរសេនាតូចទេ?

គុណ ៖ ហ្នឹងហើយវរសេនាតូចទេ ។ ចុះបើទូកថៃនេសាទឡើងពេញទឹក ពេញដីយើង ។

ធានី ៖ ចាប់បានប៉ុន្មានទូក?

គុណ ៖ ហ៉ើ! មិនដឹងច្រើនដែរ មិនគិតអី ។

ធានី ៖ ចាប់រាល់ដង ឬយូរៗចាប់បានម្ដង?

គុណ ៖ មែនទែនទៅ១-២អាទិត្យ ឬកន្លះខែ ៣ថ្ងៃចាប់បាន ។

ធានី ៖ ចាប់ពីណាមកពូដឹងទេ?

គុណ ៖ បើមែនទែនទៅវាចាប់ចូលទឹកដីយើង ក្នុងយ៉ែចេះ ព្រំដែនសមុទ្រអន្តរជាតិចេះ ព្រំដែនយើងហើយនេះប្រកចាំយាម ក្នុងយ៉ែនឹងបន្ទាយធំរបស់ថៃវាចូលមកនេះ យើងកាកៗ ។

ធានី ៖ ចាប់បានយកទៅដាក់នៅណា?

គុណ ៖ យើងយកទៅប្រគល់ឲ្យកងពល ។

ធានី ៖ ប្រជាជនវាយកទៅណា?

គុណ ៖ ប្រជាជនវាយកទៅកំពង់សោម យកឲ្យតាមុតទៅ ។ ហ្នឹងហើយ តាមុតដោះស្រាយគ្នាតាមតែទូតយើងយក ។

ធានី ៖ ទូកយើងយក តែគេបញ្ជូនមនុស្សទៅ?

គុណ ៖ មនុស្សអ្នកឯងយកទៅវិញ ។

ធានី ៖ ដឹងតាមុតយកទៅណា?

គុណ ៖ យកឲ្យថៃទាក់ទងតាមផ្លូវទូត ។

ធានី ៖ អត់ដឹង?

គុណ ៖ ខ្ញុំមិនដឹងដែរ ។

ធានី ៖ ចុះមានប៉ះបរទេសក្រៅពីថៃ?

គុណ ៖ អត់ៗដែលឃើញសោះ ។

ធានី ៖ យួន ឬក៏បរទេសផ្សេង របៀបគេដើរលេងសមុទ្រ?

គុណ ៖ អត់ៗដែលជួប អត់ដែលឮ ។

ធានី ៖ មានតែថៃ?

គុណ ៖ ហ្នឹងមានតែថៃ ដែលវាមកឈ្លានពានមកនេសាទចូលទឹកដីយើងៗចាប់ មនុស្សយើងបញ្ជូនឲ្យទៅលើ ទូកយើងទុកនៅអង្គភាពប្រើប្រាស់ ។

ធានី ៖ នៅឆ្នាំ៧៨ បានពូរៀបគ្រួសារ?

គុណ ៖ នៅសៀមរាប ។

ធានី ៖ គាត់ធ្វើការជាមួយគ្នាដែរ?

គុណ ៖ អត់ទេ គាត់ប្រជាជនធម្មតា ។

ធានី ៖ គាត់អ្នកស្រុកណា?

គុណ ៖ នៅភូមិទឹកផុស ។

ធានី ៖ នៅនោះម៉េចទៅដល់កោះកុង?

ប្រពន្ធ ៖ រត់ៗយួន ។

គុណ ៖ ចុះកាលនឹងគេយកឲ្យទៅនៅតាមព្រំដែនចូលបង្កបង្កើនផល ។

ធានី ៖ ប៉ុន្មានគ្រួសារគេយកទៅ?

គុណ : ហ៎! ច្រើនដែរ៥០-៦០គ្រួសារនឹង ។ ហ្នឹងបានគេរៀបចំឲ្យចេះយកទៅ គេថាអង្គការចាត់តាំង ។

ធានី : ខាងណាអ្នកផ្តើមគំនិត ចាត់តាំងឲ្យពូរៀប?

គុណ : អង្គការមែនទែន តាគៀងនឹងឯង កងពលតូច ថាឥឡូវអាយុអ្នកឯងត្រូវដល់ កាលនោះខ្ញុំអាយុ២៥ ត្រូវរៀបចំគ្រួសារឲ្យឈ្មោះនាងនេះៗរៀបចំ ។

ធានី : ហើយម៉េចទៅពិធីរៀបការគេ?

គុណ : ពិធីអីមិនមែនភ្លេងវាផ្ទាល់អីទេ គ្រាន់ទៅដល់៥គូ គ្រាន់ពិធីរៀបចំរឿងហូបចុកអីគគ្រឹកគគ្រេងណាស់ធំដុំ ។

ធានី : ហូបចុកម៉េចខ្លះ?

គុណ : ហូបចុក មានគោ មានជ្រូកគគ្រឹកគគ្រេង ភ្ញៀវពីលើហើយសុទ្ធតែកងទ័ពខ្លះប្រជាជនមក តែគ្មានចងដៃចងជើងគ្រាន់តែប្រសិទ្ធពរជ័យតែប៉ុននឹង ឲ្យអ្នកឯងបានជួបជុំគ្នា បានសេចក្តីសុខសេចក្តីចំរើន អាយុវែង ។

ធានី : កាលនឹងឪពុកម្តាយពូចូលរួមដែរ?

គុណ : ឪពុកម្តាយនៅកំពង់ឆ្នាំង មានបានមកណា គាត់ស្លាប់អស់ហើយ ។

ធានី : ចុះមីង?

គុណ : ទាំងអស់ប្រាប់គ្រប់គ្នា និយាយរួមទៅទោះបីគាត់នៅរស់ក៏មិនអាចមកបានដែរ ។ ពិធីរៀបចំនឹងវាគគ្រឹកគគ្រេងមែនទែនមិនធម្មតា អ្នកតូចអ្នកធំដូចយើងឥឡូវអ្នកសក្តិ៣-៤-៥ ។

ធានី : ពូស្គាល់ពួកគាត់ដែរ អ្នកមកចូលរួមពិធីការ?

គុណ : ខ្ញុំស្គាល់ទាំងអស់ តែចង់ភ្លេចឈ្មោះអស់ហើយ តាំងពីវរសេនាតូច វរសេនាធំ កងពល អនុសេនាធំ ។

ធានី : កាលនឹងតាមុតអីមានមក?

គុណ : តាមុកអត់បានមកព្រោះឆ្ងាយ មានតែតាគៀង តាញាយមកទាំងអស់ តាឡូញខាងនេសាទអត់បានមកទេ ។ គាត់អត់បានមកព្រោះនៅខាងកំពង់សោម ហើយខ្ញុំនៅខាងដងទង់ ពិធីរៀបអាពាហ៍ពិពាហ៍នឹង គ្រាន់យើងអត់អុចធូបទៀនអត់មានភ្លេង ប៉ុនពិធីជប់លៀងប្រហែលគ្មានអ្នកណាធ្វើដល់ ។ ក្នុងសម័យយើងនេះ ធ្វើអត់ដល់ទេ ។

ធានី : កាលនឹងការជាមួយពូប៉ុន្មានគូ?

គុណ : ៥គូ ។

ធានី : ៥គូ សុទ្ធតែអ្នកធ្វើការដូចពូ ឬក៏ម៉េច?

គុណ ៖ អ្នកខ្វះកងទ័ព ។

ធានី ៖ កងទ័ពធម្មតា?

គុណ ៖ ហ្នឹងហើយ ទៅដល់ចូលអនុវិទ្យាល័យកោះកុង ។

ធានី ៖ ធ្វើនៅក្នុងអនុវិទ្យាល័យនឹង?

គុណ ៖ ហ្នឹងហើយ មនុស្សនៅពេញនឹង ចង់រៀបចំពិធីអីទៅ អញ្ជើញគណអធិបតីមកប្រសិទ្ធិពរជ័យប្រជាជនយើងឲ្យផ្កា...។ យើងខុសតែអុចធូ អុចទៀន ហើយនឹងភ្លេងទេ បើកាលនឹងសំបើមណាស់ មិនធម្មតាទេ គគ្រឹកគគ្រេងណាស់ ម៉ាយប់ ម៉ាថ្ងៃទៅអញ្ជើញពិសា មានអ្នកបម្រើការងារទាំងអស់បរិបូរទៅ ។

ធានី ៖ ដល់ពេលប៉ុន្មានវៀតណាមចូលមក?

គុណ ៖ ៧៩ ។

ធានី ៖ ពូទៅណា?

គុណ ៖ ខ្ញុំរត់ទៅមករហូត ដល់អីចឹងខ្ញុំរំលាយខ្លួនឈប់ធ្វើអីទាំងអស់ ។ ដល់រត់ចូលដីថៃមិនដឹង៧០ប៉ុន្មានភ្លេចហើយ ។

ធានី ៖ ពូថានៅ៧៩ រត់ចូលទៅជុំរុំខាវឡាង?

គុណ ៖ ខាវឡាង ហ្នឹងហើយយួនដេញមកក្នុងកំឡុង៧៩ ។

ធានី ៖ ពូរត់ទៅថៃកោះកុង ខាវឡាងនឹង?

គុណ ៖ ខាវឡាងនឹងឯង ។

ធានី ៖ ប្រកចាំយាម?

គុណ ៖ ហ្នឹងហើយប្រកចាំយាម សួរអ្នកនេះរត់ទៅទាំងអស់គ្នា ។

ធានី ៖ ហើយម៉េចពូរត់ទៅនឹង មានគេដឹកនាំទៅ ឬយើងរត់ទៅខ្លួនឯង?

គុណ ៖ ចុះបើយួនចេះមកទៅចេះទៅ ។

ធានី ៖ ម៉េចបានពូមកដល់ម៉ាឡៃ?

គុណ ៖ ចុះយើងទៅជុំរុំខាវឡាង យួនគេនៅកាន់កាប់ទីក្រុង ថៃគេថាបងប្អូនកុំទៅប្រទេសទីពាអី ។ គណបក្សគេគាំទ្រយើងសុំឲ្យបងប្អូនធ្វើមាតុភូមិនិវត្តន៍ ដោយស្ម័គ្រចិត្តទៅតស៊ូដើម្បីយកទឹកដីយើងវិញ ។ នាំគ្នាមកតាមរយៈចេញពីខាវឡាងនឹងមកដល់ខ្មែម ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំចេញមក?

គុណ ៖ មែនទែនទៅ គ្មានអ្នកណាដឹកនាំមកផង គ្រាន់ថាកាលនឹងយើងនៅជុំរុំម៉ៃរ៉ូត គាត់បងប្អូននាំគ្នាទៅប្រទេសទីពា ចុះទឹកដីយើងឲ្យអ្នកណានៅ? តែខ្ញុំអត់ស្គាល់គាត់ទេ ឈ្មោះលោកសក្តិ៥

នឹង ។

ធានី ៖ សក្តិ៦ ឬសក្តិ៥?

គុណ ៖ សក្តិ៦ ថៃមានដល់សក្តិ៦ ។ ថា"គួរតែបងប្អូនធ្វើមាតុភូមិនិវត្តន៍ទៅ ទៅតស៊ូយកទឹកដីភូមិដូនភូមិស្ថាយើងវិញ ។ បងប្អូនឃើញហើយថាយួនចូលមកវ៉ៃយើង បើយើងរត់ចោលអស់ទៅប្រទេសទី៣ ចុះទឹកដីឲ្យអ្នកណានៅ" ។ បាននាំស្ម័គ្រចិត្តនៅ ក៏គេដឹកឡានមកនៅខ្មែរ ។

ធានី ៖ ខ្មែរនឹងគេហៅជំរុំអី ២០០១?

គុណ ៖ អត់ទេខ្មែរនឹងអត់ទាន់មានលេខទេ ។ កាលពីនៅខ្ញុំ មុនដំបូងខាវឡាង ខ្ញុំឡើងមកខ្មែរ យួនវាតត្បាតពេក មិនអាចនៅបាន អង្គការសហប្រជាជាតិដឹកមក២០០១ ។

ធានី ៖ ជំរុំ២០០១ជំរុំអីគេ?

គុណ ៖ ម៉ៃរូត ។ ដល់ចេញពី២០០១ អ្នកណាគេមានខ្សែមានហោ គេសម្ភាសន៍បានទៅប្រទេសទី៣ទៅ យើងនៅអត់មានអី គេដឹកមកខាវអ៊ីដាង ។ ចេញពីខាវអ៊ីដាង អង្គការសហប្រជាជាតិបងប្អូនធ្វើមាតុភូមិនិវត្តន៍ បើស្ម័គ្រចិត្តអង្គការសហប្រជាជាតិបើឲ្យ ខ្ញុំស្ម័គ្រមិនអាចរស់នៅបាន ព្រោះនៅជំរុំថៃស្លាប់រាល់ថ្ងៃ ។

ធានី ៖ ហេតុអី?

គុណ ៖ ហេតុអីមកពី ដីផលីឡូប្អូនជ្រុងគេមានរបង ហើយទាហាន៣០ម៉ែត្រ៣នាក់ មានអគ្គីសនីទាំងអស់ បងប្អូនការលោភលន់ សូម្បីតែផ្លែចេកមួយ៣បាត ។ ហើយចិញ្ចឹមរបស់អង្គការសហប្រជាជាតិ គាត់និយាយថា អង្គការសហប្រជាជាតិជួយបានម៉ារស់ទេ អត់មានបានទេ ។ មានអីលួនទៅ ទាហានឃើញបាញ់ផាប់ មួយថ្ងៃ៣-៤នាក់ម៉ាយប់ ។ និយាយរួមខាវអ៊ីដាងស្លាប់ច្រើនណាស់ ។ ម្នាក់ឯងទៅរួចខ្លួន មករួចខ្លួន ផលចំណេញរបស់អ្នកឯងបានច្រើនរមៀតប្រវែងនេះ១បាត ផ្លែចេកមួយ៣បាត ហើយស្ករមួយគីឡូ៣៥បាត ។ ហើយអង្គការជួយចិញ្ចឹមយើងមិនមែនបានគ្រប់ចំនួន ។

ធានី ៖ គេអត់ឲ្យយើងចេញក្រៅ?

គុណ ៖ អត់ឲ្យចេញទេ របងគេព័ទ្ធ ។

ធានី ៖ បើយើងលួចចេញបានចំណេញ?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ ធ្លាប់មានលួចចេញបាន?

គុណ ៖ លួចចេញបាន តាមខ្ញុំដឹងចេញបានតែមនុស្សស្រីដែលគេអ្នកឆើតឆាយគេទាក់ទាហាន ចេញបានរកស៊ីមានៗ បើយើងអត់ទេ សាមញ្ញ ចុះ៣០ម៉ែត្រ៣នាក់ ហើយភ្លើងអគ្គីសនីភ្លឺចិញ្ចាចគ្រាន់ឃើញភ្លែតផុងៗ

ធានី ៖ ដល់ពេលឆ្នាំ ៨៣ពូត្រឡប់មកភូមិដូង?

គុណ ៖ បាទ!

ធានី ៖ ហើយសុខភាព អ្នកដឹកនាំ?

គុណ ៖ បាទ!

ធានី ៖ ហើយពូមកដល់ដំបូង ឃើញទិដ្ឋភាពនៅម៉ាឡៃយើងម៉េច?

គុណ ៖ ទិដ្ឋភាពនៅនេះមានសុទ្ធតែព្រៃភ្នំ គ្មានពន្លឺថ្ងៃ ឃើញផ្ទះនៅម៉ាជុំវិញភូមិដូងនេះប្រហែលជា៥០ខ្នងប្រក់ដំបូលស្បូវ ផ្ទះនឹងមិនមែនខាងប្រជាពលរដ្ឋសុទ្ធទេ សុទ្ធតែយោធាក្រោមការដឹកនាំរបស់លោកសុខ ភាពនឹងៗ យើងធ្វើការតស៊ូ ដល់យូរៗប្រជាជនមកពីជុំវិញមក គេស្ម័គ្រចិត្តធ្វើមាតុភូមិនិវត្តន៍មកវិញនជាមួយយើងមក គាត់ក៏ចេះពង្រាយកម្លាំងតាមនឹងទៅៗ

ធានី ៖ ចុះពូស្គាល់កន្លែងសារតាំងទេ?

គុណ ៖ ថ្មីមិនស្គាល់ ខ្ញុំអ្នកកសាង មុនដំបូងសារតាំងមានអីនឹង ខំអារឈើចង់ងាប់ៗ

ធានី ៖ កន្លែងនឹងគេធ្វើអី?

គុណ ៖ សារតាំងមែនទែនទៅ ប្រទេសទាំងអស់កាលដែលយើងនៅតស៊ូខ្មែរក្រហម ទៅប្រជុំអង្គការសហប្រជាជាតិ ទៅម្តងៗចំនួនចេះកើនឡើងៗ ដល់ប្រទេសនានាគេចង់ដាក់ទូតដាក់អីជាមួយយើង សម្តេចយាយសម្តេចតាគាត់អញ្ជើញមកគេជូនសារតាំងគាំទ្រយើងនឹងទៅៗ

ធានី ៖ សម្តេចតានៅនឹងដែរ?

គុណ ៖ ហ្នឹងហើយនៅនឹងដែរ ប៉ុនសម្តេចតាអត់គង់នៅនឹងទេ ប៉ុនប្រទេសណាៗដែលគេចង់បញ្ជូនសារតាំងគាំទ្រយើង ស្តេចយាងមកទៅរៀបចំនឹងទៅៗ

ធានី ៖ កន្លែងផ្ទះស្ទូវនឹង?

គុណ ៖ ហ្នឹងហើយៗ

ធានី ៖ ហើយពូមកនៅក្បែរនឹងដែរ?

គុណ ៖ ខ្ញុំនៅតែនេះនឹង តែដល់ពេលមានពិធី គេប្រកាសប្រជាជនឲ្យទៅចូលរួម...នឹងទៅៗ

ធានី ៖ ពូនៅក្បែរសារតាំងនឹងទេ?

គុណ ៖ ខ្ញុំអត់ដែលនៅទេ ខ្ញុំនៅតែនេះរហូតៗ

ធានី ៖ នៅនេះនៅបឹងបេង?

គុណ ៖ ហ្នឹងនៅភូមិសង្កែ ។

ធានី ៖ មានពិធីអីបានពូទៅដល់កន្លែងសារតាំង?

គុណ ៖ ហ្នឹងហើយដល់អីចឹងទៅ សម្ដេចយាយសម្ដេចតា ប្រទេសណាចង់គាំទ្រកម្ពុជា គេយកសារតាំងមកជូនសម្ដេចនៅនឹង ។

ធានី ៖ សារតាំងនឹងស្អីគេ?

គុណ ៖ សារតាំង កន្លែងនឹងសម្រាប់ស្ដេចទទួលស្គាល់ដែលគេមកទាក់ទង ។

ធានី ៖ តែប៉ុននឹងឯង?

គុណ ៖ ហ្នឹងឯង ដំណាក់ស្ដេចសម្រាប់សំណាក់នៅនឹងឯង ដល់បរទេសត្រូវទំនាក់ទំនងទទួលស្គាល់ការតស៊ូរបស់ខ្មែរសម្ដេចមកទទួលសារតាំង ។

ធានី ៖ សម្ដេចសីហនុគាត់នៅជាមួយខ្មែរក្រហមដែរ?

គុណ ៖ សម្ដេច មែនទែនទៅមិនដែលឃើញ តែពេលណាប្រទេសនានាដូចប្រុយនេ ប្រទេសគាំទ្រខ្មែរផ្ញើសន្និបាទអង្គការសហប្រជាជាតិ គាំទ្រខ្មែរក្រហមក្នុងម៉ាឆ្នាំៗមានប៉ុន្មានប្រទេស ១២ ប្រទេស យាងសម្ដេចមកទទួលសារតាំងគាំទ្រព្រះអង្គក្នុងការតស៊ូ ។

ធានី ៖ មានយ៉ែម ហើយនឹងសុខ ភាព ជាអ្នកគ្រប់គ្រងនៅ១០២ ។ ចុះមានអ្នកណាគេលើយ៉ែមហើយនឹងសុខ ភាព?

គុណ ៖ អត់មានទេ មានតែតាយ៉ែមចៅហ្វាយស្រុកគេហៅគណៈប្រក ហើយភាព ខាងយោធា ។

ធានី ៖ ក្រៅពីនឹងអត់មានទៀតទេ?

គុណ ៖ អត់មានទេ ។

ធានី ៖ ចុះតាម៉ុកដែលធ្លាប់មកលេងនឹងទេ?

គុណ ៖ តាម៉ុក ពេលណាប្រជុំសារតាំងគាត់មកដែរ គាត់មកប្រមូល ។

ធានី ៖ អ្នកណាគេខ្លះ ដែលមកប្រជុំសារតាំងម្ដងៗ?

គុណ ៖ ខ្ញុំសង្កេតឃើញដែរ ឃើញខៀវ សំផន, អៀង សារី ។

ធានី ៖ ចុះសុន សេន?

គុណ ៖ សុន សេនអត់ដែលឃើញមកទេ ។

ធានី ៖ សុន សេនមិនមែនអ្នកនៅនឹងទេ?

គុណ ៖ សុន សេននៅ៣១ ។

ធានី ៖ ៣១ នៅសំពៅលូន?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ សំពៅលូន ភ្នំព្រឹក គាត់នៅនឹង?

គុណា ៖ គាត់នៅ ។

ធានី ៖ ចុះពូថាគាត់នៅខ្សែមនោះ?

គុណា ៖ ហ្នឹងខ្ញុំនៅខាងប្រជាពលរដ្ឋ ប៉ុនទីតាំងអ្នកធំៗគាត់នៅខាងសំពៅលូននឹងហើយ ។

ធានី ៖ សំពៅលូន អ្នកណាគេខ្លះទៅ?

គុណា ៖ សំពៅលូន មែនទែនមានតាសុនសេន...អ្នកហាមឃាត់មានអ្នកណា កងពលមានតារ៉ុន តាប៊ិន ស្លាប់ហើយ ហើយនឹងនាយ កន ។

ធានី ៖ តាកន?

គុណា ៖ បាទ! តាមខ្ញុំដឹង ។

ធានី ៖ ពូនៅ១០២ទេ?

គុណា ៖ ហ្នឹង១០២ ។

ធានី ៖ ចុះអៀង សារី គាត់មកធ្វើអី?

គុណា ៖ អៀង សារី គាត់ពេលណាស្តេចមកនឹង គាត់មក ។

ធានី ៖ គាត់អ្នកធំដែរ?

គុណា ៖ អៀង សារី បើមែនទែនទៅ គាត់ខាងក្រសួងការបរទេស ។

ធានី ៖ ចុះសម័យ៣ឆ្នាំ នៅពេទ្យ នៅកងពល អ្នកណាគេប្រធានកងពលទី១?

គុណា ៖ ប្រធាននឹងឈ្មោះ គឿង ស្លាប់អស់ហើយ ។

ធានី ៖ ប្រាប់ថាប្រធានធំលើគឿងនឹងទៀត?

គុណា ៖ អត់មានទេ មានតែគឿងនឹងឯង ។

ធានី ៖ ចុះកងពលនឹងក្រោមការគ្រប់គ្រងរបស់អ្នកណាគេ របស់ក្រសួង របស់អីក្តាប់?

គុណា ៖ កងពលបើមែនទែនកាលនឹង វាមិនទាន់និយាយឲ្យច្បាស់លាស់ផង ថាកងពលទី១តាម៉ុកគណៈភូមិភាគ ហើយតាគឿងកងពលទី១ ហើយសាខាចេញមកម៉ាកងពលមាន៣វរសេនាធំឈ្មោះគឿងនឹងគ្រប់គ្រងម៉ាកងពលតូចនឹង គឺមានប្រធានពេទ្យមួយមកចាត់ចែងខ្ញុំអត់អាចស្គាល់អស់ ។

ធានី ៖ ដូចពូធ្វើពេទ្យមានប្រធានពេទ្យរបស់ពូ ទ័ពមានមេកង ដូចសម័យយើងឥឡូវមានក្រសួង ដល់ពេលសម័យនោះ គេមានក្រសួងអត់ទេ?

គុណា ៖ គេអត់ហៅក្រសួងផង គេហៅថាពេទ្យកងទ័ព ។

ធានី ៖ កងទ័ពនឹងនៅក្នុងអីរបស់ក្រសួង?

គុណ ៖ អត់និយាយរឿងក្រសួងផង គេនិយាយពេទ្យយោធា ពេទ្យមូលដ្ឋាន ។

ធានី ៖ ពេទ្យនឹងអ្នកណាគេអ្នកគ្រប់គ្រង យោធាគ្រប់គ្រង ឬខាងយោធាគ្រប់គ្រង?

គុណ ៖ អត់មានប្រជាជនទេ មានខាងយោធាខាងនយោបាយកងពលអ្នកគ្រប់គ្រង ។ ពិសោធន៍ការងារ ព្យាបាលជម្ងឺយ៉ាងម៉េចៗយ៉ាងម៉េច ។

ធានី ៖ ដែលថាពូមាន៣នាក់?

គុណ ៖ ហ្នឹងហើយ ដែលវាអត់មានក្រសួងសង្គមកិច្ច អានឹងគេហៅមែន តែការគ្រប់គ្រងរបស់យោធាទាំងអស់ ។

ធានី ៖ ពូថានៅឆ្នាំ៨៣ត្រឡប់មកភូមិដូងផង ធ្វើអ្នកដឹកជញ្ជូនផង ធ្វើពេទ្យដែរអត់?

គុណ ៖ ខ្ញុំមកដល់នឹង ខ្ញុំដឹកជញ្ជូនរហូតមកទល់ឥឡូវ ។

ធានី ៖ អត់ធ្វើពេទ្យទៀតទេ?

គុណ ៖ ឈប់ហើយ ព្រោះវាវ័យចំណាស់ហើយ ។

ធានី ៖ ចុះថាដួន ជឿន មកបង្រៀនពូធ្វើពេទ្យ?

គុណ ៖ អានឹងខ្ញុំមកក្រោយ៨៣បន្តិច ។

ធានី ៖ ដួន ជឿនគាត់មកបង្រៀនដែរ?

គុណ ៖ ហ្នឹងហើយមកបង្រៀនដែរ ។

ធានី ៖ បង្រៀនហើយ ម៉េចពូអត់ធ្វើពេទ្យវិញ?

គុណ ៖ ធ្វើម៉េច បើសុខភាពមិនសូវល្អ ហើយសំខាន់ស្មារតី ។

ធានី ៖ ហើយតាដួន ជឿន គាត់មកបង្រៀន?

គុណ ៖ បង្រៀននេះ កូនសិស្សគាត់វះកាត់ ប៉ុនមូលដ្ឋានគាត់នៅកំរៀង ។

ធានី ៖ ដល់ពេល៨៥រត់ទៅនៅជុំរុំខាវអ៊ីដាង?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ បន្ទាប់មកឆ្នាំប៉ុន្មានបានពូត្រឡប់មកដល់ម៉ាឡៃ?

គុណ ៖ ..... កងទ័ពថ្មីពីដើមការគ្រប់គ្រងរបស់ភាពកងពល៤៥០ តែឥឡូវមិនដឹងអ្នកណាជាប្រធានខ្ញុំអត់ដឹង ។

ធានី ៖ នៅឆ្នាំ៨៥ ពូត្រឡប់ទៅជុំរុំខាវអ៊ីដាង ដល់ឆ្នាំប៉ុន្មានបានពូត្រឡប់មកវិញ?

គុណ ៖ ខ្ញុំត្រឡប់មកពីខាវអ៊ីដាងនឹង៨៤ ។

ធានី ៖ ៨៣មកភូមិដូង?

គុណ ៖ ភូមិដូង ៨៣ ៨៤ចូលដល់ដីថៃ យួនវៃចូលដីថៃ ។

ធានី ៖ ដល់ពេលហើយម៉េចទៀត?

គុណ ៖ នៅជុំវិញដល់ពេលនេះយើងមានទីតាំងហើយ គេឲ្យវិលមក ។

ធានី ៖ មកភូមិវិញឆ្នាំប៉ុន្មាន?

គុណ ៖ ៨៥ ។

ធានី ៖ ៨៥ ត្រឡប់មកវិញ?

គុណ ៖ ខ្ញុំមកនៅនេះវិញ ។

ធានី ៖ មកវិញ ពូឃើញទិដ្ឋភាពម៉េចដែរ?

គុណ ៖ មកនៅទិដ្ឋភាពផ្ទះឆេះ នៅសល់តែសសរ កណ្តាលព្រៃកសាងភូមិករ ខ្វះក៏ស្លាប់ប្រពន្ធ ប្តីពិការជរា ។

ធានី ៖ ហេតុអី បានស្លាប់ប្រពន្ធប្តីពិការ?

គុណ ៖ ចេះ កាលនោះវៀតណាមគេ.... ។

ធានី ៖ វាស់កាត់របងម៉េចទៅ?

គុណ ៖ របងលួសគេ កន្លែងនឹងមានសាលារៀននឹងគេដាក់អាមីនស្មាច់១៥ម៉ែត្រពីមុនរបងលួស ក្នុងរបងលួសអាគ្គារមកអាស្នួលពោតមកគ្គារ ហើយចំរូងដែកទៀត ។ យើងស្គាល់ទឹកដីយើង ហើយយួនដកថយហើយ យើងមកកសាងភូមិយើងវិញទៅ គ្រោះថ្នាក់អានឹងឯង ។

ធានី ៖ ពូមកប៉ះមីនភាគច្រើន?

គុណ ៖ ហ្នឹងហើយ ប៉ះកូនខ្ញុំខាងនោះក៏អីចឹងដែរ សុទ្ធត្រូវមីនទាំងអស់ ចុះមីនសុទ្ធតែកប់មិនធម្មតា ។

ធានី ៖ ហើយមកដល់ផ្ទះនេះរាល់ថ្ងៃត្រូវរាវដែរ?

គុណ ៖ រាវ ។

ធានី ៖ រាវខ្លួនឯង?

គុណ ៖ ជួលថៃ កាលហ្នឹងហើយឲ្យថៃធ្វើដូវឲ្យ សុទ្ធតែព្រៃ កាលនឹងប្រកខ្ញុំដីក ឲ្យថៃឈូសដូវឲ្យប្រជាជនធ្វើដំណើរសុខចិត្តឲ្យព្រៃឈើខ្វះ ។ គេមានអាសានី ខ្ញុំមានដី៤៥ម៉ែត្រ ទទឹង២០ ឲ្យគេឈូស គេយក១៥០០បាត ។

ធានី ៖ ពូប៉ះមីនប៉ះអី?

គុណ ៖ ផ្ទុះជាមួយអាត្រាក់ និយាយពីមីនមហាសែនមីន ។

ធានី ៖ អត់អីទេអាត្រាក់នឹង?

គុណ ៖ អាគ្រាក់នឹងវៀចកន់វៀចអី ផ្ទុះមិនបានរត់ចោលទាល់តែស៊ីម៉ាក់មកដោះ ។ លំបាកមែនទែន អាគ្រាក់ឈូសហើយ អាសានីឈូសអស់ទៀត ហើយអំទៅរាវគ្រាប់រាវអីទៀត ផ្ទុះអស់ទៀត ។

ធានី ៖ មកត្រូវគ្រាប់ ត្រូវអី?

គុណ ៖ ត្រូវអានេះកូនខ្ញុំអានោះ ។

ធានី ៖ ត្រូវជាអំបែង?

គុណ ៖ អំបែងរំសេវ សាហាវណាស់ ។ ហើយផ្ទុះនេះ ខ្វាក់ភ្នែកម្តាយ អាសានីឈូសអស់ហើយ ស្មាន អស់ហើយមានអីទៅដាំផ្ទុះដើរទៅដីសើមជាន់ផ្ទុះ ។ ប៉ុនឥឡូវវាអស់ហើយ បានអង្គការ ស៊ីម៉ាក់ជួយដោះស្រាយ អត់មានបញ្ហាអីទេ ។ ប៉ុនវាជួបខុបសគ្គតិចរឿងធម្មជាតិ ជីវភាព ប្រជាជននឹងឯង ។

ធានី ៖ ដល់ពេលពូមកវិញ ពាក់កណ្តាល៨៥មកដល់វិញហើយធ្វើស្រែចំការលែងធ្វើកងដឹកជញ្ជូន?

គុណ ៖ ហ្នឹងលែងហើយ ប៉ុនយូរៗដូចគេត្រូវការម៉ាយាមគេឲ្យដឹកជញ្ជូន ។

ធានី ៖ កាលនឹងនៅមានសង្គ្រាមទៀត?

គុណ ៖ សង្គ្រាមតិចតួច ។

ធានី ៖ រហូតដល់ឆ្នាំប៉ុន្មានលែងមានសង្គ្រាម?

គុណ ៖ មែនទែនទៅ ខ្ញុំប៉ុន្មានទេដែលយើងសមាហរណកម្មរួបរួមសម្តេច ។

ធានី ៖ ឆ្នាំប៉ុន្មាន ពូចាំទេ?

គុណ ៖ អត់ចាំទេ ប៉ុនស៊ីម៉ាក់មកនៅវិញ្ញា ដល់ក្រោយស៊ីម៉ាក់ប៉ុន្មាន ខ្ញុំអត់បានកត់ត្រាទុកដែរ ។

ធានី ៖ ដល់ក្រោយទៅធ្វើម៉េចបានមានដីនៅខ្ទួនឯង?

គុណ ៖ ចុះព្រំដែន គេកំណត់ថាឲ្យបងប្អូនខំសាងភូមិសាងករ... ព្រោះថៃវា ។

ធានី ៖ យើងកសាងខ្ទួនឯង?

គុណ ៖ ហ្នឹងហើយកសាងខ្ទួនឯង រាវមីនខ្ទួនឯង ហើយដូលគេមានលុយមានកាក់ដែលគេមានបច្ចេកទេសខាងសរាវមីន ហើយឲ្យលុយកាក់ទៅ ។

ធានី ៖ ចុះពូមានដឹងថាកាលឆ្នាំ៩០ជាងអីមានគេប្រមូលសហករណ៍?

គុណ ៖ អត់មានទេ ។

ធានី ៖ ប្រមូលទ្រព្យសម្បត្តិឯងជនចូលអីអត់មាន?

គុណ ៖ អត់ៗមាន ។

ធានី ៖ ចុះពូដឹងថា អ្នកណាគេអ្នកបង្កើតកកើតវា?

គុណ ៖ មែនទែន មានលោក សុខ ភាព និងលោក យ៉ែម ។

ធានី ៖ ហេតុអីបានគាត់កកើត?

គុណ ៖ ព្រោះកាលនឹងយើងកាន់កងទ័ពអី វៀតណាមវ៉ៃកម្ទាំងយើងថយគេវ៉ៃពីវៀតណាមមក ដូច្នេះយើងយកព្រៃជាមូលដ្ឋានធ្វើការតស៊ូ ។

ធានី ៖ ពូដឹងថាកាលពីមុនម៉ាឡៃស្ថិតនៅក្នុងខេត្តណាទេ?

គុណ ៖ ម៉ាលៃខេត្តបាត់ដំបង ។

ធានី ៖ ចុះកាលសម័យ៣ឆ្នាំស្ថិតនៅក្នុងតំបន់អី?

គុណ ៖ អត់ដឹងលេខតំបន់អីដែរ ។

ធានី ៖ ដឹងស្ថិតនៅស្រុកអីម៉ាឡៃ បើយើងគិតកាលពីមុន?

គុណ ៖ ម៉ាឡៃនឹងស្រុកស៊ីសាផុនខាងត្បូង ដល់នោះគេហែកទៅជាខេត្តបន្ទាយមានជ័យ ។

ធានី ៖ កាលមុនស្រុកស៊ីសាផុនត្រឹមណាដល់ត្រឹមណា?

គុណ ៖ ម៉ាឡៃស្ថិតនៅស៊ីសាផុតនឹង បើតាមមែនទែនទៅភូមិឥឡូវគេហៅស៊ីសាផុន ទើបឥឡូវគេបំបែកថ្មីអំដឹងខាងថ្មី បើចាស់អត់អាចដឹងទេ ។

ធានី ៖ ចុះអំដឹងថាអ្នកណាគេដឹងថាកាលពីមុនម៉ាឡៃស្ថិតនៅក្នុងណា ហើយមានប្រជាជនរស់នៅអត់?

គុណ ៖ កាលពីដើមមកគ្មានប្រជាជនរស់នៅទេ កាលដែលយើងមិនទាន់មានការវ៉ៃ ច្រូងច្រាងក្នុងសង្គ្រាម ។

ធានី ៖ កាលសម័យសង្គមរាស្ត្រនិយមអីមានអត់?

គុណ ៖ អត់មានប្រជាជននៅទេ ។

ធានី ៖ ចុះម៉េចយើងការពារព្រំដែនយើងបាន?

គុណ ៖ អត់ទេ រឿងនឹងមានព្រៃច្រើនណាស់ ទាហានដែលបង្ក្រាបខ្មែរសេរីៗឆ្ងាយណាស់នៅភ្នំនឹងដល់អីចឹងថៃវាលួចកាប់ឈើកាប់ព្រៃធ្វើស្រែ យើង ។ ដល់អីចឹងគួរសរសើរដែរ មោទនភាពរបស់ប៉ុលពតពីដើម... គាត់រុញប្រជាជននៅគៀកព្រំដែន ។

ធានី ៖ ឆ្នាំប៉ុន្មានពូដឹង?

គុណ ៖ កាលនឹងខ្ញុំដឹង៧/៩ហើយ ។

ធានី ៖ ដែលរុញមកគៀកនឹង?

គុណ ៖ ហ្នឹងហើយ ។

ធានី ៖ អត់ដឹង មុននឹងទៀតអត់ដឹងទេ?

គុណ ៖ អត់ដឹងទេ ។

ធានី ៖ តែពេលមកដល់នឹងឃើញអត់មានផ្ទះប្រជាជន?

គុណ ៖ អត់មានរលីង ។

ធានី ៖ ចុះមានផ្លូវមានអី?

គុណ ៖ អត់មានទេ ។

ធានី ៖ ពីសង្គមចាស់អីអត់មានដែរ?

គុណ ៖ អត់មានរលីង មានផ្លូវថៅកែយ៉ាវថៃពីដើមគេដឹកឈើដឹកអីលក់ ។

ធានី ៖ ពីត្រឹមណាដល់ត្រឹមណា?

គុណ ៖ អឺ! ថៅកែយ៉ាវឆ្ងាយដែរ ។

ធានី ៖ បើយើងគិតពីត្រឹមសាលាស្រុកយើងទៅ?

គុណ ៖ ថៅកែយ៉ាវមិនដឹងចូលទឹកដីខ្មែរត្រឹមណា ប៉ុនអុំឃើញទឹកដីខ្មែរម៉ាដូវភ្នំយាយសំ អូរត្រង់ដីលើ អូរត្រង់ដីក្រោម មានផ្លូវលំ ។

ធានី ៖ មានផ្លូវលំ?

គុណ ៖ ហ្នឹងហើយផ្លូវលំចាស់កាត់ឈើទាលទាំងអោបៗ អុំឃើញ ។

ធានី ៖ នៅខាងណាវិញភ្នំយាយសំ?

គុណ ៖ យាយសំនៅក្រោយបន្ទាយទី២ ។

ធានី ៖ នៅខាងតាគង់ខាងអី?

គុណ ៖ ហ៊ឺ! អត់ដល់នឹងទេ ។

ធានី ៖ ខាងអូរស្រឡៅ?

គុណ ៖ ហ្នឹងហើយ ហួសអូរសំព័រតិច ។

ធានី ៖ មានតែប្រកនឹងទេ?

គុណ ៖ ហ្នឹងហើយ សួរគេទៅនៅត្រង់ណាភ្នំយាយសំ គេចង្អុរប្រាប់ ហើយខាងកើតភ្នំយាយសំនឹង គឺអូរត្រង់ដីលើ អូរត្រង់ដីក្រោម នឹងមានផ្លូវលំនឹងដែលទៅថៅកែយ៉ាវពីដើម ។

ធានី ៖ ពូស្គាល់ម៉ក់ហឺន?

គុណ ៖ ម៉ក់ហឺនខ្ញុំស្គាល់ ។

ធានី ៖ ម៉ក់ហឺនមានទំនប់មួយ មានទេ?

គុណ ៖ មាន ។

ធានី ៖ មានពីពេលណាមក?

គុណ ៖ ទំនប់នឹង តាមអ៊ំមកនៅនេះពុស្សូរតែទំនប់ម៉ក់ហឹន តែវាខ្ពស់ទាបអត់ដឹងដែរ ។

ធានី ៖ ពូដឹងថាវាមានពីពេលណា?

គុណ ៖ ទំនប់នឹង...កាលខ្ញុំដូនទៅ.....ឃើញទំនប់នឹងហើយ ។

ធានី ៖ តែទំនប់នឹងជ្រៅឬរាក់ គ្រាន់ឃើញវាមានទឹកធំ?

គុណ ៖ បើនិយាយពីប្រភពត្រីទឹកសាបសំបើមណាស់ ។

ធានី ៖ ឥឡូវនៅសំបូរអីចឹង?

គុណ ៖ ឥឡូវដូចថាគេថយហើយ ។ និយាយពីត្រីស្ដោរវិញមានអា៧-៨គីឡូក៏មានដែរ ពីឆ្នាំណាៗ អត់ដឹង ។

ធានី ៖ ពូដឹងថាម៉ក់ហឹននៅខាងណានៃសាលាឃុំអូរសំព័រ ឬអូរស្រឡៅ?

គុណ ៖ ហឺ! អូសំព័រនៅនេះ អូរស្រឡៅនៅនេះដែរ ។

ធានី ៖ អីចឹងទំនប់ម៉ក់ហឹននៅក្នុងស្រុកអី?

គុណ ៖ ចេះក្នុយឯងជិះឡានទៅពីនេះទៅមានដើមចាន់គិរីមួយចំប៉ះផ្លូវ ហើយគេគេចទៅចេះ ម៉ក់ហឹន នៅនេះ ។ ដល់អីចឹងទំនប់នៅនោះទេ ។

ធានី ៖ ពីព្រោះពេលខ្ញុំជិះមកឃើញសាលាបឋមសិក្សាម៉ក់ហឹន សាលារៀន?

គុណ ៖ ហ្នឹងហើយ ឡើងទៅលើវិញ នៅកូនភ្នំមួយតូច ។

ធានី ៖ នៅក្បែរកូនភ្នំនឹង?

គុណ ៖ ហ្នឹងហើយនៅពីមុខកូនភ្នំនឹង ។

ធានី ៖ នៅពីខាងណាសាលារៀន បើយើងជិះពីនេះទៅ?

គុណ ៖ ចំមើលបើយើងជិះពីម៉ាខ្សែទៅ ទៅដល់នោះចំកណ្ដាលផ្លូវមានដើមចាន់គិរីជាប់នោះគេងាកចេះ ដល់អីចឹងឡើងពីនេះទៅប្រហែល១០០ម៉ែត្រឃើញភ្នំម៉ក់ហឹនមួយ ទំនប់នៅនេះ ។

ធានី ៖ ទំនប់នៅកៀកភ្នំនឹង?

គុណ ៖ នៅពីមុខភ្នំនឹង ជាប់ថៃ ។

ធានី ៖ បើជិះពីនេះទៅយើងមើលអត់ឃើញ?

គុណ ៖ មើលអត់ឃើញទេ ។ បើអ៊ំស្គាល់ដោយសារការដឹកជញ្ជូនទេ ស្គាល់គ្រប់កន្លែងទាំងអស់ ។

ធានី ៖ ឆ្ងាយដែរ បើយើងជិះពីផ្លូវនេះមើលអត់ឃើញ?

គុណ ៖ មើលអត់ឃើញ ។ ប៉ុន្ដផ្លូវនេះគេឲ្យឈ្មោះថា៥០២ៗមែនទែនទៅចំនុចខ្វាំងរបស់គេនៅបឹង បេង ។

ធានី ៖ កាលពេលសង្គ្រាមនេះ?

គុណ : បាទ! ហើយដល់អីចឹងទៅផ្លូវបំបែកចុះមកខ្វាងសាប់នេះ អឺចង់និយាយឲ្យអស់ទៅឆ្នាំប៉ុន្មានមិនចាំឆ្នាំ.....កម្លាំងដឹកជញ្ជូនគេនាំគ្នារៀបចំធ្វើផ្លូវ៥០២មីនច្រើនណាស់យើងមិនអាចធ្វើដំណើរបានទេ ខាងអង្គការដឹកនាំឲ្យយកមីនគោនម្នាក់១គ្រាប់ៗធ្វើម៉េចចុចកំទេចមីនវៀតណាមដាក់នឹង១ថ្ងៃៗលីគ្រាប់ ។ អីចឹងបានថាចាប់ពីខ្វាងសាប់ចុះមកអីនឹងហើយអ្នកនាំគ្នាធ្វើចុចមីនផ្ទាក់មកដល់មាត់អូរនេះណាខ្វាងសាប់ ។ ទើបឥឡូវឲ្យអង្គការស៊ីម៉ាក់រាវៗមកទិសដៅតាមផ្លូវចាស់ហើយ ។

ធានី : ចុះខ្វាងសាប់នឹងនៅភូមិអីគេ?

គុណ : ភូមិខ្វាងសាប់នឹង ។

ធានី : ស្រុកអីគេ?

គុណ : ស្រុកម៉ាឡៃ ។

ធានី : មានតែឃុំតាគង់?

គុណ : ចំមើលណាភូមិតាគង់ ឃុំអូរសំព័រ ឃុំបឹងបេង ឃុំម៉ាឡៃ ខ្វាងសាប់គេដាក់ឃុំមួយដែរ ។

ធានី : អត់មានទេ?

គុណ : បើអីចឹងមានឃុំទួលពង្រ ចង់ភ្លេចតា ។

ធានី : ដូចថាអ៊ីដែលអឹរៀបរាប់មកច្រើនជំនាន់ ចង់សួរអ៊ីថាពីរបបមួយរហូតមកដល់ឥឡូវវាខុសគ្នាយ៉ាងម៉េចទៅ សម័យ៣ឆ្នាំ សម័យ៧៩ រហូតដល់សម័យយើងឥឡូវមានភាពខុសគ្នាម៉េច?

គុណ : តាមការរស់នៅរបស់អឹសម័យសង្គមរាស្ត្រនិយមមនុស្សស្គាល់បុណ្យបាបច្រើន ។ ដល់សម័យលន់ នល់ សម័យសាធារណរដ្ឋ សម័យនោះបុណ្យបាបមានតិច អំពើបាបមានច្រើន តែវាមិនកើនប៉ុន្មានទេ វា២០ភាគរយទេ ។ បើសម័យប៉ុលពតនេះ និយាយលែងកើត និយាយទៅវាហួសពេក ទោះបីអ្នកឯងមិនគាំទ្រ ក៏ត្រូវតែគាំទ្រ ។ សម័យសម្តេចហ៊ុន សែននេះគ្រាន់តែជួសជុលទេ បើតាមមែនទែនទៅនិយាយថាឱវាទច្បាប់មានគ្រប់កន្លែងទាំងអស់ហើយសាសនាក៏រីកចំរើនច្បាប់ក៏មាន ដល់មនុស្សប្រព្រឹត្តិផ្ទុយច្បាប់ច្រើនដែរ ។

ធានី : ចង់សួរចិត្តពូវាល្អកន្លែងណា វាមិនល្អកន្លែងណា?

គុណ : សម័យសម្តេចមែនទែនវាបាន៨០ភាគរយ ។ គ្រាន់ថារឿងមិនល្អមិនមែនរដ្ឋាភិបាលអ្នកធ្វើ ។

ធានី : សំខាន់យើងធ្វើអីសេរី?

គុណ : បាទ! សេរីទៅវាខ្ពស់ជាងច្បាប់ ។

ធានី : យ៉ាងម៉េចខ្លះ ដូចម៉ាឡៃឥឡូវយ៉ាងម៉េចខ្លះក្មេងៗ?

គុណ : ម៉ាឡៃឥឡូវ បើមែនទែនវាគ្រាន់បើជាងមុន ចង់និយាយថាខាងសាសនាក៏មានគេអប់រំ ច្បាប់របស់រាជរដ្ឋាភិបាល ។ បើអីចឹងអ្នកមិនស្គាល់លោកក៏ស្គាល់លោកដែរ ចេះធ្វើបុណ្យធ្វើទាន

ហើយតាមវត្តអារាមវារីកចំរើនទោះបីខុះខាតម៉េចក៏ដោយ មិនឲ្យព្រះសង្ឃអត់ចង្ហាន់ទេ តាមហេមន្តសនរដូវភ្ជុំបិណ្ឌ ចូលឆ្នាំអីក៏ដោយ គឺប្រជាជនទៅគគ្រឹកគគ្រេង។ ជាមោទនភាពរាជរដ្ឋាភិបាល មិនមែនដូចរបបមុនទេ របបប៉ុលពត។

ធានី : ចង់សួរពូថា នៅក្នុងសម័យ៣ឆ្នាំ ពូធ្លាប់ជួយអ្នកណាគេឲ្យរួចជីវិត ឬក៏ជួយឲ្យបាយ?

គុណ : មែនទែន ខ្ញុំនិយាយឲ្យត្រង់បើខ្ញុំនិយាយខុសហ៊ានឲ្យរន្ទះបាញ់ខែចែត្ររដូវប្រាំង ព្រោះថ្នាំពេទ្យ ដែលអ៊ំនៅកោះកុង អ៊ំស្ពាយមក ឆ្លងកាត់៣ខែនាំគ្នាឈឺគ្រុនមិនដឹងមានអីសង្គ្រោះគ្នា ដូច្នេះឲ្យគេ ជួយឲ្យគ្នាបានរស់រានមានជីវិតធ្លាក់មកដល់ដីថៃ។ អ្នកខ្លះរកឈ្មោះខ្ញុំរាល់ថ្ងៃ អាខ្លះទៅដល់អូស្រ្តាលី ប៉ែលស៊ិច ប៉ុនរកខ្ញុំអត់ឃើញ ប៉ុនខ្ញុំជួយសង្គ្រោះគេ។

ធានី : ជួយគេយ៉ាងម៉េចខ្លះ?

គុណ : ជួយចេះ ឧទាហរណ៍ថាគ្រុនចាញ់ ដល់អីចឹងខ្ញុំឲ្យថ្នាំលេប ដល់ជាទៅដើរជាមួយគ្នាទាំងអស់ អាមួយទៀតរត់មកវាឈ្មោះតាន់ យួនបាញ់របួសជើងរបួសដៃ ខ្ញុំទៅហែកក្រណាត់ខោអាវខ្លួនឯងជួយចាក់ថ្នាំទៅជា។ រត់មកដល់ដីថៃ ឥឡូវយើងបានសុខដុមរមនា យើងបែកគ្នាមិនដឹងទៅណាអស់។

ធានី : ជួយបាន២នាក់នឹង?

គុណ : ហេ! ជួយច្រើន អ្នកឈឺគ្រុនច្រើនណាស់ បើអ្នករបួសបានម្នាក់។

ធានី : របួសដែលគាត់និយាយ?

គុណ : ហ្នឹងហើយសួរប្រពន្ធខ្ញុំ។

ធានី : ចុះអ្នកឈឺគ្រុនស្គាល់ឈ្មោះគាត់?

គុណ : អត់ស្គាល់ទេ ព្រោះអង្គភាព១៦៨មានស្រីមានប្រុស ហើយគ្រួសារយោធា ពួករោងចក្រកម្មករនៅកំពង់សោមមកដល់ភូមិ។ ដល់គេមានថ្នាំមិនដឹងម៉េច សុខចិត្តរស់ម្នាក់ឯងម៉េចដល់អីចឹងឲ្យទៅក៏ជាទៅ ដើរទៅជាមួយគ្នា។ អ៊ំសូមប្រាថ្នាអនាគតទៅ ឬបច្ចុប្បន្នជួយខ្ញុំវិញ។

ធានី : ចង់សួរអ៊ំថា អ៊ំរត់មកតាមកងពល១៦៨ទាំងអស់គ្នា?

គុណ : មកជាមួយគ្នា ដល់មកដល់ដីថៃ គេបែកគ្នាអស់ទៅ គេចែកជំរុំគ្នា អាខ្លះគេធ្វើតេស្តបានទៅបរទេស វាស្រាវជ្រាវរកខ្ញុំដែរ តែរកខ្ញុំមិនឃើញ តែជួបបានម្នាក់ តែឥឡូវបែកគ្នាទៀតហើយ។

ធានី : ជួបនៅណា?

គុណ : កាលខ្ញុំនៅម៉ៃរូតនឹង ឈ្មោះ អំ ហើន គេទៅប៉ែលស៊ិច ម៉ាខែគេផ្ញើមក១០០ហ្វ្រង់។

ធានី ៖ រាល់ថ្ងៃនឹង?

គុណ ៖ អត់ទេ កាលនឹងនៅជំរុំ ។

ធានី ៖ គាត់ផ្ញើឲ្យ?

គុណ ៖ ហ្នឹងហើយ ដល់ឥឡូវខ្ញុំផ្ញើមាតុភូមិនិវត្តន៍ស្ម័គ្រចិត្តមក ខ្ញុំអត់បានមានស្អីៗឲ្យគាត់ រកគ្នាអត់ឃើញ ។ ឃើញម្នាក់នឹងឯងការជួយសង្គ្រោះគ្នា តែអ្នកដទៃទៀតមិនដឹងទៅណាអស់ ចេះជួយគ្នាទៅ ខ្ញុំបានជួយគេច្រើនដែរ ។ ហើយធនធានមក ដោយសារខ្ញុំធ្វើពេទ្យនៅកោះកុងការគ្រប់គ្រងពេទ្យមកមានថ្នាំគ្រុនចាញ់ ថ្នាំពេលណាក្តៅ ផ្តាសាយ មានសព្វបែបយ៉ាង ។ បងប្អូនដើរសំដៅជាមួយខ្ញុំមានគ្រុនមានញាក់ឈឺស្ទូវគ្នា ។ កាលនោះយើងគ្មានចាយលុយទេ អីចឹងបានកន្ទងមកនេះ ចូលដីថៃមកដូចគ្នាដែរ មិនដែលថៃណាខោកក្បាលបាន ហ្នឹងក្រៅពីនឹងសុទ្ធ...។ ហើយខ្ញុំធ្វើអំពើល្អ គឺអំពើទាំងអស់នឹងបានល្អ រហូតដល់រាល់ថ្ងៃហ្នឹងខ្ញុំក៏មិនក្រខ្ញុំក៏មិនមាន គេរៀបរាប់អានខ្ញុំរហូត ។

ធានី ៖ ពូដែលពូពាក្យថាផ្សះផ្សា?

គុណ ៖ ផ្សះផ្សាខ្ញុំដឹងហើយ ផ្សះផ្សាជាតិ មែនទែនទៅមិនថាម៉េចទេ បើខុសឆ្គងអធ្យាស្រ័យផងព្រោះការផ្សះផ្សាមិនចាញ់មិនឈ្នះ កុំសម្តេចអនុគ្រោះឲ្យទេ ។

ធានី ៖ ទាក់ទងនឹងការផ្សះផ្សា បើយើងធ្វើគួរតែធ្វើនៅជិតគ្នា យើងធ្វើនៅឆ្ងាយពីគ្នា?

គុណ ៖ ២នឹងបើមែនទែនទៅយើងនៅជិតគ្នាល្អជាង អាជិតគ្នាយើងផ្សះផ្សា ចាំទៅរកអាឆ្ងាយ យើងនៅជិតគ្នាផ្សះមិនបានផង ទៅឲ្យគេឆ្ងាយផ្សះម៉េចបាន ។

ធានី ៖ ពូនៅសល់រូបថត ឬវត្ថុអីចាស់ៗពីមុនមកទេ នៅសេសសល់ទេមកដល់រាល់ថ្ងៃ?

គុណ ៖ ខ្ញុំមែនទែនទៅកាលខ្ញុំនៅជំរុំ ប៉ុនវាបោះបង់ចោលអស់ហើយ ។ កាលខ្ញុំនៅជំរុំខ្ញុំធ្វើអំណោយឈាម ដល់ប្រជាពលរដ្ឋយើង ដោយសាររងទុក្ខិចតាមព្រំដែន ។ អង្គការសហប្រជាជាតិគាត់ដឹកជញ្ជូនយកទៅដល់ជំរុំខាវអ៊ីដាងក្នុងសង្កាត់១៧ខាវអ៊ីដាង គេសុំធ្វើអំណោយឈាមដល់ជនរងគ្រោះ ។ ខ្ញុំបូមឈាមហើយខ្ញុំសន្ទប់ ខ្ញុំសុខចិត្តធ្វើម៉េចឲ្យខ្មែរយើងរស់ ហើយខ្ញុំមានវ៉ាលីបោះចោលកាល កាល៧៩យួនវ៉ៃចូល ។

ធានី ៖ មានទុកនៅ?

គុណ ៖ អត់ កាល៧៩ដែលខ្ញុំមកនៅនេះហើយ៨៤ យួនវ៉ៃលើកទី២ ខ្ញុំបោះចោលខ្ញុំយកតែខ្លួនមករស់នៅដីថៃ ។

ធានី ៖ ចុះពូមាននៅសល់រូបថតចាស់?

គុណ ៖ អត់មានទេ ខ្ញុំបោះចោលអស់ ដេញចាប់ៗ មិនជឿគ្រួសារខ្ញុំចុះ ធ្វើអំណោយឈាមដល់បងប្អូនដែលរងគ្រោះក្នុងសង្គ្រាមតាមព្រំដែនៗ

ធានី ៖ អត់មានអីនៅទៀត វត្ថុចាស់អត់មាន?

គុណ ៖ ចុះកាលនឹងទៅតែខ្លួន ផ្ទះឯងទៅចោលទាំងអស់ ចុះគេដេញបាញ់មានកាំភ្លើងធំម៉ាំងៗ ផាកខ្លួនអត់ចង់រួចទេៗ

ធានី ៖ ពូមិញពូប្រាប់ថា ពូឈ្មោះមាស គុណ ពូមានឈ្មោះហៅក្រៅទេ?

គុណ ៖ ខ្ញុំអត់មានផងៗ

ធានី ៖ ព្រោះឪពុកពូឈ្មោះប្រែង ដល់ពូឈ្មោះផ្សេង?

គុណ ៖ មាស គុណៗ

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

គុណ ៖ ខ្ញុំមានបងប្អូន៥ ៗ

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គុណ ៖ ស្រី១ ប្រុស៤ ៗ

ធានី ៖ ហើយគាត់នៅរស់ទាំង៤?

គុណ ៖ ស្លាប់អស់ហើយនៅសល់៣ ៗ

ធានី ៖ សល់៣ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គុណ ៖ ស្រីស្លាប់អស់ហើយនៅសល់៣ ៗ

ធានី ៖ គាត់នៅណា?

គុណ ៖ មួយនៅកំពង់ចាមនៅស្រុកៗ

ធានី ៖ គាត់នៅស្រុកណាផ្សេង?

គុណ ៖ ស្រុកកំណើតនៅជាមួយខ្ញុំនៅភូមិតាចេស ប៉ុនដល់កាលសង្គ្រាមវាបែកបាក់គ្នាក៏បានប្រពន្ធនៅនឹងទៅៗ ហើយនៅបងមួយ និងខ្ញុំមួយ គាត់នៅវត្តថ្មី ឃុំតាចេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងៗ ហើយខ្ញុំកំណើតនៅនឹងដែរ ប៉ុនខ្ញុំបែកមកនៅម៉ាឡៃៗ

ធានី ៖ ចុះពូខស្សរាហ៍ទៅលេងស្រុកកំណើត?

គុណ ៖ ខ្ញុំទៅលេង៤ដងៗ

ធានី ៖ ខស្សរាហ៍ទៅលេងទៅមក?

គុណ ៖ បាទ!

ធានី ៖ គ្រួសារពូឈ្មោះអី?

គុណ ៖ សោម យ៉េន ។

ធានី ៖ គាត់មានឈ្មោះហៅក្រៅទេ?

គុណ ៖ អត់មានផង ។

ធានី ៖ មានកូនប៉ុន្មាននាក់?

គុណ ៖ កូន៨ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គុណ ៖ ប្រុសមានតែ២ ។

ធានី ៖ ស្រី៦?

គុណ ៖ បាទ! ហើយបានរៀបអាពាហ៍ពិពាហ៍អស់ហើយ នៅសល់តែ៣ទេ ។

ធានី ៖ ពូមានលេខទូរស័ព្ទទេ?

គុណ ៖ លេខទូរស័ព្ទខ្ញុំអត់មានទេ មានតែកូនខ្ញុំ ខ្ញុំអត់អ្នកប្រើ ។

ធានី ៖ កូននៅជាមួយពូ?

គុណ ៖ បាទ!

ធានី ៖ សុំលេខតិចមើល?

គុណ ៖ សេរីទៅរៀនបាត់ ។

ធានី ៖ លេខប៉ុន្មាន?

គុណ ៖ កូនខ្ញុំនេះដែរ ធ្វើPassort ធ្វើVisaទៅថៃ ។ ខ្ញុំចង់លើកមតិមួយឲ្យក្មួយឯងពិចារណា(ស្តាប់មិនសូវឮ) ......... ។

ធានី ៖ ពិបាកក្នុងការរស់នៅ?

គុណ ៖ លំបាកក្នុងការប្រើប្រាស់ប្រាក់ ។ ក្មួយឯងគិតមើលកូនជ្រូកទិញមក ១៣០ថ្ងៃលុយបាតដល់លក់ទៅវិញគេឲ្យលុយរៀល ។ ឧទាហរណ៍ថាជ្រូកកើតជម្ងឺឈឺក្នុងម៉ាគីឡូសាច់ដែលលក់បាន៧៦-៧៥ ...(ស្តាប់មិនបាន) ។

ធានី ៖ ពូមានអីចង់បន្ថែមទៀតទេ?

គុណ ៖ អត់មាន....(ស្តាប់មិនបាន) ។

ធានី ៖ អរគុណច្រើន ពូ រឿងនេះជារឿងរបស់រដ្ឋាភិបាលទាំងអស់គ្នា ខ្ញុំអត់សូវដឹងទេ ។

គុណ ៖ ជួយពិចារណាទាំងអស់គ្នា ។

ធានី ៖ អត់ទេ ព្រោះពួកខ្ញុំខាងអង្គការ អត់មានពាក់ព័ន្ធនឹងការងាររបស់រដ្ឋៗគេការងារផ្សេង ពួកខ្ញុំការងារផ្សេង ។ ហើយការងារពួកខ្ញុំមកនេះគឺធ្វើទាក់ទងនឹងរឿងប្រវត្តិសាស្រ្ត រឿងសរសេរ

សៀវភៅ ដើម្បីឲ្យក្មេងៗក្រោយបានអានបានអី ដឹងពីស្រុកម៉ាឡៃយ៉ាងម៉េច ។ អរគុណពូច្រើន ។

«ចប់»